ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ
For purchase information please visit
www.cambodianchristianresources.com/dfd

# ការរីកចម្រើន ក្នុងភាពជាសិស្សរបស់ ព្រះយេស៊ូវ

*គម្រោងនៃការបង្កើតសិស្ស*

## គបស៦

NAVPRESS
Discipleship Inside Out®

សាឡូមកម្ពុជា
www.smcambodia.org

NavPress
Discipleship Inside Out®

NavPress គឺជាព័ន្ធកិច្ចនៃការបោះពុម្ពរបស់ The Navigators ដែលជាអង្គការគ្រីស្ទបរិស័ទអន្តរជាតិ ហើយជាអង្គការដែលឈានមុខគេខាងការអភិវឌ្ឍផ្នែកព្រលឹងវិញ្ញាណរបស់មនុស្ស។ NavPress បានប្ដេជ្ញាចិត្តក្នុងការជួយមនុស្សឲ្យមានការលូតលាស់ផ្នែកព្រលឹងវិញ្ញាណ ហើយឲ្យមានអំណរទៅនឹងជីវិតដ៏មានន័យ ព្រមទាំងឲ្យមានសង្ឃឹមតាមរយៈធនធាននៃការសិក្សាផ្ទាល់ខ្លួន ឬការសិក្សាជាក្រុមដែលក្រុម The Navigators បាននិពន្ធ ពីព្រោះមូលដ្ឋានគ្រឹះនៃធនធានទាំងនេះបានដកស្រង់ចេញពីព្រះគម្ពីរ ហើយក៏ផ្ដល់ភាពងាយស្រួលក្នុងការអនុវត្តដល់វប្បធម៌ផ្សេងៗទៀតផងដែរ។

បកប្រែដោយ៖ បេសកកម្មសាឡូមកម្ពុជា និង សកម្មភាពកម្ពុជា
Translated by: Shalom Mission Cambodia - http://www.smcambodia.org
and ACTION Cambodia - http://www.actioncambodia.org

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោកគ្រូ សាំង ឈិនហូរ, លោកគ្រូ ហុង សុភក្ដិ, លោក ជួប ប៊ុនហាក់,
លោកស្រី កង សុគន្ធរ័ត្ន, លោក ផេង វណ្ណៈ, លោក ឈាង បូរ៉ា,
លោក ម៉ែន ជំនោ និង សកម្មភាពកម្ពុជា

សូមថ្លែងអំណរអរគុណដល់ លោក គឹម សីហា, លោក សួន សាយ័ន្ត, អ្នកស្រី ឆាយ សូដាលីន និង កញ្ញា សុគន្ធ ចិន្ដាមណី ដែលមានចំណែកក្នុងការអភិវឌ្ឍសៀវភៅនេះ។

ក្រុមយើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ឆ្នាំ១៩៥៤ ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្ដែសំណេរនៅក្នុងអត្ថបទទាំងមូល យើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្ដេចសង្ឃរាជ ជួន ណាត។
ព្រមជាមួយនឹងការប្រើប្រាស់កម្មវិធីត្រួតពិនិត្យអក្ខរាវិរុទ្ធ
និងវេយ្យាករណ៍ យូនីកូដខ្មែរ របស់ ស.ស.ឈ.ន.ក.
Using the SBBIC Unicode Khmer Spelling Checker
and Grammar Checker - http://www.sbbic.org

© 1973, 1980, 2006, 2014 by The Navigators
រក្សាសិទ្ធិគ្រប់យ៉ាង © ១៩៧៣, ១៩៨០, ២០០៦, ២០១៤ ដោយ The Navigators
All rights reserved. No part of this publication may be reproduced in any form without written permission from NavPress, P.O. Box 35001, Colorado Springs, CO 80935.
www.navpress.com

NAVPRESS and the NAVPRESS logo are registered trademarks of NavPress. Absence of ® in connection with marks of NavPress or other parties does not indicate an absence of registration of those marks.

ISBN 978-0-9890481-5-6

Cover design by Arvid Wallen
Cover illustration by Michael Halbert
Interior design by The DesignWorks Group
រចនាអត្ថបទភាសាខ្មែរ ៖ លោក សេង ធា, លោក ម៉ែន ជំនោ និង លោក ផុន ស្រីអែម
Creative Team: Dan Rich, Kathy Mosier, Arvid Wallen, Pamela Poll, Pat Reinheimer, Kathy Guist
Original DFD Author: Chuck Broughton
Revision Team: Dennis Stokes, Judy Gomoll, Christine Weddle, Ralph Ennis
អត្ថបទគម្ពីរ © រក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល-ដកស្រង់ដោយមានការអនុញ្ញាត
Printed by Glory Printing House

# គបស៦ | មាតិកា


ចូរឲ្យដោយគ្មានសំណោង ៥

**ជំពូកទី១**

ដូចម្ដេចដែលហៅថាសិស្សរបស់ព្រះយេស៊ូវ? ៧

**ជំពូកទី២**

អ្នកវាប់រងដែលមានទំនួលខុសត្រូវ ៣១

**ជំពូកទី៣**

ការជួយអ្នកដទៃស្វែងរកព្រះគ្រីស្ទ ៥៩

**ជំពូកទី៤**

ការចាក់គ្រឹះឲ្យរឹងមាំ ៨៣

**ជំពូកទី៥**

ទស្សនៈពិភពលោក ១០៥






# ចូរឲ្យដោយគ្មានសំណាង

ព្រះយេស៊ូវមានបន្ទូលទៅសិស្សរបស់ទ្រង់ថា "...អ្នករាល់គ្នាបានទទួលទទេ ត្រូវឲ្យទទេដែរ" (ម៉ាថាយ ១០:៨)។ យើងមានឱកាសដើម្បីហុចព្រះពរដែលព្រះជាម្ចាស់បានប្រទានមកយើងដល់អ្នកដទៃទៀត។

ព្រះជាម្ចាស់បើកឱកាសថ្មីដល់លោកអ្នក នៅពេលដែលទ្រង់បំផ្លាស់បំប្រែលោកអ្នក។ ព្រះជាម្ចាស់ធ្វើការតាមរយៈលោកអ្នកដើម្បីប្រទានពរដល់អ្នកដទៃផ្សេងទៀត។ នៅពេលដែលលោកអ្នកមានការផ្លាស់ប្រែខាងឯវិញ្ញាណ ហើយថែមទាំងសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនជាប់ជាប្រចាំ នោះនឹងបណ្ដាលឲ្យលោកអ្នកចេះចែកចាយព្រះពរដល់អ្នកដទៃ។ នៅពេលដែលលោកអ្នកចែកចាយជាមួយអ្នកដទៃ នោះលោកអ្នកនឹងឃើញថា លោកអ្នកនឹងកាន់តែមានចិត្តអរសប្បាយថែមទៀត។ ព្រះជាម្ចាស់មិនត្រឹមតែប្រទានអំណោយទានដល់លោកអ្នកប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ថែមទាំងឲ្យលោកអ្នកស្គាល់សេចក្ដីពិតបន្ថែមទៀត ដើម្បីឲ្យលោកអ្នក

អាចចែកចាយពីអ្វីដែលលោកអ្នកបានសិក្សានោះទុកជាប្រយោជន៍សម្រាប់អ្នកដទៃផងដែរ។ ជារឿយៗ ព្រះវិញ្ញាណបរិសុទ្ធនឹងប្រើប្រាស់ ការរីកចម្រើន ពាក្យសម្ដី និងទង្វើរបស់លោកអ្នក ដើម្បីឲ្យលោកអ្នកអាចលើកទឹកចិត្តដល់អ្នកដើរតាមព្រះយេស៊ូវផ្សេងៗទៀត។ ប្រហែលជាទ្រង់នឹងប្រើប្រាស់ជីវិតលោកអ្នកឲ្យធ្វើជាក្លិនក្រអូបដ៏ជាទីចាប់អារម្មណ៍មួយ ដើម្បីដាស់តឿនអ្នកមិនជឿឲ្យទទួលស្គាល់ថា ពួកគេត្រូវការព្រះយេស៊ូវគ្រីស្ទ។

> អើ ល្អណាស់ហ្ន៎ គឺជើងនៃអ្នកនោះដែលដើរលើភ្នំ ជាអ្នកដែលនាំដំណឹងល្អមក ហើយប្រកាសប្រាប់ពីសេចក្តីមេត្រី ជាអ្នកដែលនាំដំណឹងល្អពីការប្រសើរមក ហើយថ្លែងប្រាប់ពីសេចក្តីសង្គ្រោះ គឺជាអ្នកដែលពោលដល់ក្រុងស៊ីយ៉ូនថា ព្រះនៃឯងទ្រង់សោយរាជ្យ (អេសាយ ៥២:៧)

ការសិក្សាលើប្រធានបទនៅក្នុងសៀវភៅនេះនឹងជួយលោកអ្នកឲ្យរីកចម្រើនក្នុងការបង្កើតសិស្ស។ ប្រធានបទនៃសៀវភៅនេះមានរួមដូចជា៖

- ដូចម្ដេចដែលហៅថាសិស្សរបស់ព្រះយេស៊ូវ?
- អ្នករ៉ាប់រងដែលមានទំនួលខុសត្រូវ
- ការជួយដល់អ្នកដទៃស្វែងរកព្រះគ្រីស្ទ
- ការចាក់គ្រឹះឲ្យរឹងមាំ
- ទស្សនៈពិភពលោក

ជំពូកទី

# ១

# ដូចម្ដេចដែលហៅថាសិស្ស របស់ព្រះយេស៊ូវ?

និយមន័យដ៏សាមញ្ញបំផុតនៃពាក្យថា “សិស្ស” មានន័យថា “អ្នករៀនសូត្រ” ឬក៏ “អ្នកដើរតាម”។ លោក សូក្រាត (Socrates) លោក យ៉ូហានបាទីស្ទ (John the Baptist) និង លោក មហាត្មៈ គន្ធី (Gandhi) ពួកគាត់សុទ្ធតែជាអ្នកដែលមានសិស្ស ប៉ុន្តែការក្លាយទៅជាសិស្សម្នាក់របស់ព្រះយេស៊ូវ គឺខុសដាច់ស្រលះពីពួកគាត់ទាំងនោះ មានន័យថា វាលើសពីការដើរតាមការដឹកនាំនានារបស់មនុស្សលោកយើងនេះទៅទៀត។ អ្នកដើរតាមព្រះយេស៊ូវគ្រប់រូបសុទ្ធតែបានទទួលការអញ្ជើញឲ្យចូលរួមនៅក្នុងទំនាក់ទំនងដ៏ពិសេសមួយដែលជាអភ័យឯកសិទ្ធិ និងជាឱកាសយ៉ាងអស្ចារ្យបំផុតសម្រាប់ពួកគេ។

# ការអញ្ជើញឲ្យចូលរួមក្នុងទំនាក់ទំនង ដ៏ពិសេសរបស់ព្រះយេស៊ូវ



១. សូមអានកណ្ឌគម្ពីរ យ៉ូហាន ១៥:១២-១៦។ តើព្រះយេស៊ូវបានពណ៌នាពីតួនាទីក្នុងនាមទ្រង់ជាចៅហ្វាយ ខុសពីចៅហ្វាយនៃលោកីយ៍នេះយ៉ាងដូចម្ដេច?

តើអភ័យឯកសិទ្ធិ និងឱកាសមួយចំនួនដែលព្រះយេស៊ូវបានប្រទានដល់សិស្សរបស់ទ្រង់មានអ្វីខ្លះ?

២. នៅក្នុងកណ្ឌគម្ពីរ ហេព្រើរ ១៣:៥-៦ ព្រះជាម្ចាស់បានសន្យាថា លោកអ្នកនឹងមានទំនាក់ទំនងដ៏ពិសេសជាមួយទ្រង់។ តើលោកអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច ចំពោះសេចក្ដីសន្យារបស់ព្រះជាម្ចាស់នៅពេលដែលលោកអ្នករស់នៅដើម្បីទ្រង់?

៣. សូមអានកណ្ឌគម្ពីរ លូកា ១៤:២៥-៣៣។

ក) ហេតុអ្វីបានជាមានមនុស្សខ្លះមិនចង់មានទំនាក់ទំនងបែបនេះជាមួយព្រះយេស៊ូវ? (ខ២៦-២៧)

ខ) តើអ្នកដែលចង់ក្លាយជាសិស្សរបស់ព្រះយេស៊ូវត្រូវពិចារណាលើអ្វីខ្លះ?

គ) តាមការយល់ឃើញរបស់លោកអ្នក សូមគិតទៅមើលថា ហេតុអ្វីបានជាព្រះយេស៊ូវមិនសព្វព្រះហឫទ័យឲ្យមានអ្វីផ្សេងទៀតនៅក្នុងជីវិតយើងដែលមកប្រជែងនឹងទ្រង់? (សូមអានកណ្ឌគម្ពីរ ម៉ាថាយ ១០:៣៧ ដើម្បីយល់ឲ្យច្បាស់ពីអត្ថន័យនៃពាក្យ **លះអាល័យ**)

ឃ) តើលោកអ្នកឆ្លើយតបទៅនឹងព្រះរាជបញ្ជារបស់ព្រះយេស៊ូវដែលថា ឲ្យលះអាល័យអ្វីៗទាំងអស់ ដើម្បីដើរតាមទ្រង់យ៉ាងដូចម្តេច?

> *អស់អ្នកដែលឲ្យនូវអ្វីដែលគាត់មិនអាចរក្សាទុកបាន ដើម្បីឈោងចាប់នូវអ្វីដែលគាត់មិនអាចបាត់បង់បាន អ្នកនោះមិនឆ្កួតទេ។*
>
> លោក ជីម អិលីយិត (Jim Elliot)
> ដកស្រង់ចេញពីសៀវភៅ *The Journals of Jim Elliot*

៤. យោងតាមខគម្ពីរក្នុងតារាងខាងក្រោមនេះ តើព្រះយេស៊ូវបានមានបន្ទូលថា សិស្សរបស់ទ្រង់ត្រូវប្រកាន់ខ្ជាប់នូវអ្វីខ្លះ? សូមលើកខយោងមួយចំពោះខនីមួយៗ បន្ថែមទៅលើចម្លើយរបស់លោកអ្នក (ព្រះគម្ពីរដែលមានខយោងមានដូចជា ព្រះគម្ពីរជាភាសាខ្មែរបច្ចុប្បន្ន និងព្រះគម្ពីរគ្រីស្ទបរិស័ទខ្មែរ)។

| ខគម្ពីរ | ការប្រកាន់ខ្ជាប់ | ខយោង |
|---|---|---|
| យ៉ូហាន ៨:៣១-៣២ | | |
| យ៉ូហាន ១៣:៣៤-៣៥ | | |
| យ៉ូហាន ១៥:៨-១០ | | |

៥. សូមប្រើបទគម្ពីរពីសំណួរមុនៗ បន្ទាប់មកសង្ខេបនិយមន័យនៃ ភាពជាសិស្សរបស់ព្រះយេស៊ូវ។

“*នៅក្នុងសម័យក្រុមជំនុំដំបូង ប្រសិនបើមានគេហៅលោកអ្នកថាជាអ្នកដើរតាមព្រះគ្រីស្ទ នោះគេច្បាស់ជារំពឹងចង់ឃើញលោកអ្នកចេះមានទំនាក់ទំនងល្អទាំងមនុស្ស និងព្រះជាម្ចាស់ ហើយមានការផ្លាស់ប្រែក្នុងជីវិត។*

*អត្ថសញ្ញាណនេះ គឺមានភាពច្បាស់លាស់ណាស់ក្នុងសម័យកាលព្រះគ្រីស្ទ។ ការហៅនរណាម្នាក់ជាអ្នកដើរតាមព្រះយេស៊ូវ មិនមានភាពខុសគ្នាទៅនឹងការហៅនរណាម្នាក់ថា “គាត់ជាអ្នកជីកទំនិញ ឬនាងជាវេជ្ជបណ្ឌិតម្នាក់” នោះឡើយ។ វាបានចង្អុលបង្ហាញពីអភ័យឯកសិទ្ធិ និងទំនួលខុសត្រូវលើតួនាទីរបស់ពួកគេក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូវ។ ហើយវាបានបញ្ជាក់យ៉ាងច្បាស់លាស់ពីចរិតលក្ខណៈរបស់ពួកគេ ព្រមទាំងបានពន្យល់ពី មូលហេតុនៃការរស់នៅ ការពិចារណា និងទង្វើរបស់ពួកគេផងដែរ។*

លោកបណ្ឌិត យ៉ូសែប ស្តូវែល (Dr. Joseph Stowell)

ដកស្រង់ចេញពីសៀវភៅ *Following Christ*

# សិស្សគឺជាអ្នករៀនសូត្រ



ព្រះយេស៊ូវគឺជាអ្នករៀនសូត្រដែលមិនចេះចប់មិនចេះហើយ ពេលដែលទ្រង់គង់នៅផែនដី។ កាលពីទ្រង់នៅវ័យកុមារ យើងឃើញថា ទ្រង់បានស្តាប់ ហើយនិងសួរសំណួរជាច្រើននៅក្នុងព្រះវិហារ (លូកា ២:៤៦)។ អំឡុងពេលដែលទ្រង់បំពេញព័ន្ធកិច្ច យើងឃើញថា ទ្រង់កំពុងជំរុញសិស្សរបស់ទ្រង់ថា "ចូររៀនសេចក្តីប្រៀបប្រដូចពីដើមល្វា" (ម៉ាថាយ ២៤:៣២)។ អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរបានមានប្រសាសន៍ពីជីវិតរបស់ព្រះយេស៊ូវនៅលើផែនដីនេះថា "ទោះបើទ្រង់ជាព្រះរាជបុត្រាក៏ដោយ គង់តែទ្រង់បានរៀនស្តាប់បង្គាប់ ដោយសារការដែលទ្រង់រងទុក្ខលំបាកទាំងប៉ុន្មាននោះដែរ" (ហេព្រើរ ៥:៨)។

៦. ស្តេច សាឡូម៉ូន បាននិពន្ធសុភាសិតជាច្រើនសម្រាប់អស់អ្នកដែលចង់ក្លាយជាអ្នករៀនសូត្រ។ ហេតុអ្វីបានជាការដែលលោកអ្នកបើកចិត្តទទួលយកសេចក្តីបង្រៀនមានសារៈសំខាន់អស់មួយជីវិត? (សុភាសិត ៤:១១-១៣, ២០-២៦)

៧. តើយើងអាចរៀនសូត្រមកពីនរណាខ្លះ?
សុភាសិត ៤:១

សុភាសិត ២៧:១៧

ម៉ាថាយ ១១:២៩

យ៉ូហាន ៦:៤៥

ហេព្រើរ ៣:១៣

ហេព្រើរ ១៣:៧

៨. ហេតុអ្វីបានជាការមានសហគមន៍មួយដែលអាចផ្តល់សេចក្តីណែនាំផ្សេងៗមានសារៈសំខាន់ចំពោះលោកអ្នក?
(សុភាសិត ១១:១៤, ១៥:២២)

៩. សូមអានកណ្ឌគម្ពីរ សុភាសិត ២៤:៣០-៣៤។ តើលោកអ្នកអាចរៀនបានអ្វីខ្លះពីមនុស្សរឹងរូស និងពីមនុស្សមិនទទួលយកសេចក្ដីបង្រៀនដែលជាមនុស្សគ្មានប្រាជ្ញា?

១០. តើលោកអ្នកចូលចិត្តរៀនសូត្រដែរឬទេ? សូមស្រមៃទៅមើលថាប្រសិនបើលោកអ្នករស់នៅបានដប់ឆ្នាំទៅមុខទៀតដោយគ្មានការរៀនសូត្រសោះ តើវានឹងជះឥទ្ធិពលលើជីវិតរបស់លោកអ្នកយ៉ាងដូចម្ដេច?

## ការលះបង់ដើម្បីធ្វើជាសិស្សរបស់ព្រះយេស៊ូវ



ជារឿយៗ ការរស់នៅតែងតែមានការលះបង់ជាច្រើន ប៉ុន្តែអ្វីដែលសំខាន់គឺកម្រិតនៃការលះបង់ និងរង្វាន់ដ៏ពិតដែលលោកអ្នកនឹងទទួលបានវិញនោះទេ។

១១. តើលោកអ្នកអាចនឹងត្រូវលះបង់អ្វីខ្លះ ដើម្បីក្លាយទៅជាសិស្សរបស់ព្រះគ្រីស្ទបាន? (លូកា ៩:៥៧-៦២)

តើលោកអ្នកនឹងត្រូវបាត់បង់អ្វីខ្លះ ប្រសិនបើលោកអ្នកមិនព្រមលះបង់អ្វីៗទាំងអស់ ដើម្បីក្លាយទៅជាសិស្សរបស់ព្រះគ្រីស្ទ?

១២. សូមអានកណ្ឌគម្ពីរ រ៉ូម ១២:១-២។ សូមពន្យល់ពីអត្ថន័យនៃឃ្លា "ការថ្វាយយញ្ញបូជារស់"៖

១៣. សូមអានកណ្ឌគម្ពីរ លូកា ៩:២៣-២៦។

ក) តាមការយល់ឃើញរបស់លោកអ្នក តើឃ្លាថា "លះកាត់ចិត្តខ្លួនឯង" មានអត្ថន័យដូចម្ដេច?

ខ) តើឃ្លាថា “ទាំងផ្ទុកឈើឆ្កាងខ្លួនរាល់តែថ្ងៃ” មានអត្ថន័យដូចម្ដេច?

គ) តើលោកអ្នកអាច “នឹងបានជីវិតវិញ” យ៉ាងដូចម្ដេច?

> *ការធ្វើជាសិស្សរបស់ព្រះយេស៊ូវតម្រូវឲ្យយើងបែរមកធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយការលះបង់ចោលរបៀបវារៈរបស់យើងផ្ទាល់ដោយការបន្ទាបខ្លួន។ ការលះកាត់ចិត្តខ្លួនឯងដោយការផ្ទុកឈើឆ្កាងខ្លួនមកតាមព្រះយេស៊ូវ មានន័យថា លោកីយ៍នេះអាចនឹងសម្លាប់យើង ពីព្រោះយើងមិនបានដើរតាមផ្លូវរបស់វា ប៉ុន្តែយើងទាំងអស់គ្នាបានត្រៀមខ្លួនជាស្រេចចំពោះការទាំងនេះរួចទៅហើយ ពីព្រោះព្រះជាម្ចាស់បានត្រាស់ហៅយើងឲ្យដើរនៅក្នុងផ្លូវខុសពីលោកីយ៍។*
>
> លោក ដារ៉េល ប៉ក់ខ៍ (Darrell Bock)
>
> ដកស្រង់ចេញពីសៀវភៅ *NIV Application Commentary*

១៤. ដោយសារតែលោកអ្នកបានសិក្សាអត្ថបទព្រះបន្ទូលក្នុងសំណួរ ទី៧-១៣រួចមកហើយ ដូច្នេះសូមចំណាយពេលដើម្បីសញ្ជឹងគិតពីជីវិតលោកអ្នកដោយការអធិស្ឋាន។ តើមានផ្នែកណាខ្លះដែលលោកអ្នកគួរផ្លាស់ប្រែ ដើម្បីត្រាប់តាមបំណងព្រះហឫទ័យរបស់ព្រះយេស៊ូវឲ្យបានល្អប្រសើរជាងមុន? តើព្រះគ្រីស្ទសព្វព្រះហឫទ័យឲ្យលោកអ្នកប្តេជ្ញាចិត្តទៅលើអ្វីខ្លះ?

> “*ព្រះគុណដែលមានតម្លៃថោក គឺជាព្រះគុណដែលគ្មានភាពជាសិស្ស គ្មានការផ្ទុកឈើឆ្កាង គ្មានព្រះយេស៊ូវដែលទ្រង់បានយកកំណើតជាមនុស្សហើយមានព្រះជន្មគង់នៅសព្វថ្ងៃ ប៉ុន្តែព្រះគុណដែលមានតម្លៃថ្លៃ គឺប្រៀបបានទៅនឹងកំណាប់ដែលកប់លាក់ទុកក្នុងចម្ការ ហើយកាលបើមានអ្នកណារកឃើញកំណាប់នោះគាត់នឹងត្រេកអរក្នុងការលក់ទ្រព្យរបស់ខ្លួនទាំងអស់ ដើម្បីទិញវា។ ព្រះគុណពិតជាមានតម្លៃណាស់ ពីព្រោះអស់អ្នកដែលចង់បានព្រះគុណនោះត្រូវតែលះបង់ទាំងជីវិតខ្លួន ហើយនោះគឺជាព្រះគុណ ពីព្រោះមានតែព្រះគុណតែមួយគត់ដែលអាចផ្តល់ជីវិតដ៏ពិតដល់មនុស្សបាន។*
>
> លោក ដេទ្រិខ ប៊ុនហូហ្វ័រ (Dietrich Bonhoeffer)
> ដកស្រង់ចេញពីសៀវភៅ *The Cost of Discipleship*

# ឧស្សាហ៍ និងការដាក់វិន័យ



១៥. ព្រះគម្ពីរសញ្ញាថ្មីបានប្រៀបធៀប
ជីវិតនៃការដើរតាមព្រះយេស៊ូវទៅនឹង
ការរត់ប្រណាំង។ សូមអានកណ្ឌគម្ពីរ ១កូរិនថូស ៩:២៤-២៧។

ក) តើសាវ័ក ប៉ុល បានមានប្រសាសន៍ថាយើងគួររត់ប្រណាំងបែបណា?

ខ) សូមសរសេរគោលការណ៍សំខាន់ផ្សេងៗទៀតស្តីពីការរត់ប្រណាំង។
តើយើងអាចយកគោលការណ៍ទាំងនេះមកអនុវត្តលើការរត់ប្រណាំង
ក្នុងនាមជាសិស្សរបស់ព្រះយេស៊ូវអស់មួយជីវិតបានយ៉ាងដូចម្តេច?

គ) តើរបៀបនៃការរត់ប្រណាំងក្នុងជីវិតរបស់លោកអ្នកសព្វថ្ងៃនេះ ដូចទៅនឹងការរត់ចម្ងាយហាសិបម៉ែត្រ ឬក៏ការរត់ចម្ងាយឆ្ងាយបែបម៉ារ៉ាតុង? ហេតុអ្វី?

១៦. កណ្ឌគម្ពីរ ហេព្រើរ ១២:១-២ ផ្ដល់អត្ថន័យបន្ថែមទៀតស្ដីពីការរត់ប្រណាំងនេះ។

ក) តើមានអ្វីខ្លះដែលអាចរាំងការរត់ប្រណាំងរបស់អ្នកជឿមិនឲ្យដល់ទីព្រ័ត្របាន?

ខ) តើលោកអ្នកគួររត់យ៉ាងដូចម្ដេច?

គ) តើភ្នែករបស់លោកអ្នកគួរសម្លឹងទៅឯណា នៅពេលដែលលោកអ្នករត់?

ឃ) តើគំរូរបស់ព្រះយេស៊ូវបានជំរុញចិត្តលោកអ្នកឲ្យរត់ទៅមុខ
យ៉ាងដូចម្ដេច?

១៧. នៅកណ្ឌគម្ពីរ ២ធីម៉ូថេ ២:៣-៦ សាវ័ក ប៉ុល បានប្រៀបធៀបអ្នកជឿទៅនឹងមនុស្សបីប្រភេទ។

ក) តើមនុស្សទាំងបីប្រភេទនោះមានមុខងារអ្វី?

ខ) សូមជ្រើសរើសយកមនុស្សម្នាក់ក្នុងចំណោមមនុស្សទាំងនោះ រួចពណ៌នាបន្ថែមថាតើជីវិតបែបនេះអាចតំណាងឲ្យ ការយកចិត្តទុកដាក់ និងឧស្សាហ៍នៃភាពជាសិស្សរបស់ព្រះគ្រីស្ទបានដោយរបៀបណា។

១៨. សូមអានកណ្ឌគម្ពីរ ហេព្រើរ ៦:១១-១២។ តើឧស្សាហ៍ និង
ការដាក់វិន័យជាប់ពាក់ព័ន្ធទៅនឹងភាពជាសិស្សរបស់ព្រះគ្រីស្ទ
យ៉ាងដូចម្ដេច?

រៀងរាល់ពេលដែលយើងចង់បំពេញសកម្មភាពណាមួយនោះយើងត្រូវធ្វើតាមជំហាន៤យ៉ាងដូចនេះ៖ ទី១ ការមានបំណងចិត្ត ទី២ ការសម្រេចចិត្ត ទី៣ ការប្ដេជ្ញាចិត្ត ទី៤ ការដាក់វិន័យ។ ឧទាហរណ៍៖ មានបុរសម្នាក់មានបំណងចិត្តចង់ចំណាយពេលជាមួយព្រះជាម្ចាស់មុនពេលគាត់ទៅធ្វើការ។ គាត់បានទទួលស្គាល់ថា ដើម្បីឲ្យមានពេលវេលាគ្រប់គ្រាន់ គាត់ត្រូវតែក្រោកពីព្រឹកព្រលឹម
ដូច្នេះ គាត់ក៏សម្រេចចិត្តក្រោកនៅម៉ោង ៥:០០នាទីព្រឹក។



នៅថ្ងៃបន្ទាប់នោះគាត់ក៏ដេកជ្រុល ពីព្រោះការមានបំណងចិត្ត និង ការសម្រេចចិត្តរបស់គាត់តែឯងមិនអាចធ្វើឲ្យគាត់ក្រោកពីគ្រែបាននោះឡើយ។ បន្ទាប់មកគាត់ក៏បានប្ដេជ្ញាចិត្តប្រើនាឡិការោទ៍ ដើម្បីជួយដាស់គាត់ឲ្យក្រោកពីដំណេក។



នៅពេលដែលនាឡិកាបានចាប់រោទ៍ នោះហើយជាពេលដែលគាត់ត្រូវដាក់វិន័យដោយបិទសំឡេងនាឡិកា ហើយត្រូវក្រោកពីដំណេក ដើម្បីឲ្យអាចចំណាយពេលជាមួយព្រះជាម្ចាស់បាន។



ការដាក់វិន័យដ៏ទៀងទាត់អាចជួយបង្កើតទម្លាប់ល្អ។ ភាពទៀងទាត់ទាមទារឲ្យមានការជឿទុកចិត្តលើកម្លាំងដែលព្រះជាម្ចាស់បានប្រទានមក។ វាទាមទារឲ្យមាន ដួងចិត្ត គំនិត និងការខំប្រឹងប្រែងជាប្រចាំថ្ងៃ។

១៩. យោងតាមកណ្ឌគម្ពីរ ភីលីព ៣:១២-១៥ តើអត្តចរិតបែបណាដែលសម្គាល់បានថា គាត់ជាអ្នកដើរតាមព្រះយេស៊ូវដ៏ពេញវ័យម្នាក់?

តើលោកអ្នកយល់ថា អត្តចរិតបែបណាដែលអាចសម្គាល់បានថា គាត់ជាអ្នកជឿដែលមិនទាន់ពេញវ័យម្នាក់?

២០. តើសាវ័ក ប៉ុល បានបង្រៀនអ្វីខ្លះអំពីឧស្សាហ៍ដែលមាននៅក្នុងកណ្ឌគម្ពីរ កូល៉ុស ៣:១៧?

២១. តើមានចំណុចណាខ្លះក្នុងជីវិតប្រចាំថ្ងៃ
ដែលលោកអ្នកគួរតែនៅបន្តហ្វឹកហាត់
ការដាក់វិន័យឲ្យកាន់តែល្អប្រសើរឡើង
នោះ? តើលោកអ្នកអាចធ្វើការនេះបាន
យ៉ាងដូចម្តេច?



២២. លើសពីការដាក់វិន័យ និងឧស្សាហ៍ តើសិស្សរបស់ព្រះយេស៊ូវគួរមាន
អត្តចរិតបែបណាទៀត? (២កូរិនថូស ១១:២-៣)

ដើម្បីធ្វើជាសិស្សដ៏ស្មោះត្រង់ និងមានភក្តីភាពចំពោះព្រះគ្រីស្ទ
តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

២៣.ហេតុអ្វីបានជាអត្តចរិតរបស់លោកអ្នកមានសារៈសំខាន់ខ្លាំងម្ល៉េះ ក្នុងនាមជាសិស្សរបស់ព្រះគ្រីស្ទ? (សុភាសិត ៤:២៣)

## សំណើខគម្ពីរមួយសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់



លូកា ៩:២៣

រួចទ្រង់មានព្រះបន្ទូលទៅមនុស្សទាំងអស់ថា បើអ្នកណាចង់មកតាមខ្ញុំ ត្រូវឲ្យអ្នកនោះលះកាត់ចិត្តខ្លួនឯង ទាំងផ្ទុកឈើឆ្កាងខ្លួនរាល់តែថ្ងៃ ហើយមកតាមខ្ញុំចុះ។

លូកា ៩:២៣

# សៀវភៅកំណត់ហេតុរបស់ខ្ញុំ

ព្រះយេស៊ូវត្រាស់ហៅលោកអ្នកមក ដើម្បីធ្វើជាអ្នកដើរតាមទ្រង់ដែលជាសិស្ស របស់ទ្រង់។ សូមសរសេរកំណត់ហេតុស្តីពីដំណើរនៃភាពជាសិស្សរបស់ទ្រង់។ ក្នុងដំណើរនេះ តើមានរឿងអ្វីដែលសំខាន់ជាងគេបំផុតចំពោះលោកអ្នក? តើមានអ្វីដែលពិបាកជាងគេបំផុត? តើលោកអ្នកចង់ហ្វឹកហ្វឺនអត្តចរិតនៃភាព ជាសិស្សរបស់ទ្រង់បន្ថែមទៀតត្រង់ចំណុចណាខ្លះ ដើម្បីឲ្យវាបានកាន់តែប្រសើរ ឡើង?

សូមប្រើរូបភាពខាងក្រោមនេះ ដើម្បីសរសេរពីរឿងសំខាន់ទាក់ទងនឹង មនុស្ស ការសម្រេចចិត្ត និងការផ្គត់ផ្គង់របស់ព្រះជាម្ចាស់នៅក្នុងដំណើរនៃភាពជាសិស្ស ត្រង់ចំណុចអតីតកាល បច្ចុប្បន្នកាល និងក្តីសង្ឃឹមនាអនាគតកាល។



# ចំណុចគួរចងចាំ

សូមពិនិត្យប្រធានបទបន្ទាប់បន្សំនៅក្នុងជំពូកនេះឡើងវិញ ហើយយកវាមកធ្វើជាគម្រោងមេរៀន ដើម្បីសង្ខេបជំពូកនេះដោយគំនិតលោកអ្នកផ្ទាល់។

# ការចូលឲ្យបានស៊ីជម្រៅ

សូមពិចារណាលើពាក្យទូន្មានរបស់ព្រះយេស៊ូវនៅក្នុងកណ្ឌគម្ពីរយ៉ូហាន ១២:២៤-២៥ ចំពោះអស់អ្នកដែលចង់ធ្វើជាសិស្សរបស់ទ្រង់៖ “ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើគ្រាប់ស្រូវដែលធ្លាក់ចុះទៅដីមិនងាប់ទេ នោះក៏នៅតែ១ដដែល តែបើងាប់វិញ នោះក៏បង្កើតផលជាច្រើនឡើង អ្នកណាដែលស្រឡាញ់ជីវិតខ្លួន នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលស្អប់ជីវិតខ្លួននៅលោកីយ៍នេះវិញ នោះនឹងរក្សាជីវិតទុក ដរាបដល់អស់កល្បរៀងទៅ”។ ចូរប្រៀបធៀបចំណុចនេះទៅនឹងពាក្យទូន្មានរបស់សាវ័ក ប៉ុល នៅក្នុងកណ្ឌគម្ពីររ៉ូម ១២:១។

តើលោកអ្នកយល់ថា ការលះអាល័យខ្លួនឯង (ឬការថ្វាយជីវិតទុកជាយញ្ញបូជារស់) មានលក្ខណៈដូចម្ដេច?

ប្រសិនបើលោកអ្នកយល់ថា លោកអ្នកស្លាប់ខាងឯបាប និងខាងឯលោកីយ៍ តើការនោះអាចនឹងជួយលោកអ្នកឲ្យរស់នៅក្នុងភាពជាសិស្សរបស់ព្រះយេស៊ូវបានដោយរបៀបណា?

សូមបញ្ចប់ប្រយោគនេះជាមួយឃ្លារបស់លោកអ្នកផ្ទាល់៖ ប្រសិនបើខ្ញុំបាន ស្លាប់ខាងឯបាប និងខាងឯលោកីយ៍ហើយ នោះខ្ញុំនឹង...

ជំពូកទី

# ២

# អ្នករ៉ាប់រងដែលមាន ទំនួលខុសត្រូវ

ភាពជាអ្នកទទួលការរ៉ាប់រង គឺមានការជាប់ទាក់ទងទៅនឹងការចាត់ចែងទ្រព្យសម្បត្តិរបស់នរណាម្នាក់ផ្សេងទៀត។ អ្នករ៉ាប់រង គឺប្រៀបដូចជាអ្នកដែលទទួលយកការគ្រប់គ្រងលើប្រាក់កាស ឬក៏អង្គការណាមួយ។ អ្នកដទៃផ្សេងទៀតទុកចិត្តនឹងគាត់ក្នុងការរៀបចំចាត់ចែងយ៉ាងឆ្លាតវៃជំនួសពួកគេ។ ដូចគ្នាផងដែរ ដោយសារតែព្រះជាម្ចាស់បានទិញយើងរាល់គ្នាដោយព្រះលោហិតរបស់រាជបុត្រាទ្រង់ នោះមានន័យថា គ្រប់របស់ទាំងអស់រួមទាំងជីវិត និងទ្រព្យសម្បត្តិរបស់យើង សុទ្ធតែជាកម្មសិទ្ធិរបស់ទ្រង់។ ដោយសារតែនៅថ្ងៃអនាគត យើងនឹងត្រូវរៀបរាប់ពីគ្រប់អ្វីៗទាំងអស់របស់យើងនៅចំពោះព្រះជាម្ចាស់ ដូច្នេះយើងគួរធ្វើជាអ្នករ៉ាប់រងដែលមានទំនួលខុសត្រូវចំពោះពេលវេលា ថវិកា អំណោយទាន និងរាងកាយរបស់យើងផងដែរ។

# អ្នកគ្រប់គ្រងធនធានរបស់ព្រះជាម្ចាស់









១. តើសាវ័ក ប៉ុល បានមានប្រសាសន៍យ៉ាងណា អំពីទំនុកចិត្តដែលព្រះជាម្ចាស់បានប្រទានមកលោកអ្នក? (១កូរិនថូស ៤:១-២)

សូមពន្យល់ថា ការនេះមានន័យដូចម្តេចចំពោះលោកអ្នក។ លោកអ្នកប្រហែលជាត្រូវប្រើខយោង ដើម្បីជួយឲ្យចម្លើយរបស់លោកអ្នកកាន់តែមានភាពប្រសើរឡើង។

២. តើមានចំណុចណាខ្លះដែលលោកអ្នកអាចមានភាពស្មោះត្រង់ចំពោះអ្វីដែលព្រះជាម្ចាស់បានប្រទានឲ្យលោកអ្នក?

សុភាសិត ៣:៩-១០

១កូរិនថូស ៦:១៩-២០

អេភេសូរ ៥:១៥-១៦

១ពេត្រុស ៤:១០

៣. តើអ្វីទៅដែលបង្ហាញឲ្យឃើញថា អ្នកបម្រើមានភាពស្មោះត្រង់? (ម៉ាថាយ ២៥:១៤-៣០)

“ *ដោយសារតែព្រះជាម្ចាស់មានលក្ខណៈជាអ្នកប្រទានឲ្យ ដូច្នេះយើងទាំងអស់គ្នាដែលជាអ្នកមានចំណែកនៅក្នុង ព្រះជន្មរបស់ព្រះជាម្ចាស់តាមរយៈព្រះគ្រីស្ទ ក៏ទទួល ការត្រាស់ហៅមក ដើម្បីឲ្យមានលក្ខណៈជាអ្នកផ្តល់ឲ្យ ផងដែរ។ ហើយអ្វីដែលយើងត្រូវថ្វាយនោះមិនមែនថ្វាយ របស់ដែលនៅសេសសល់នោះឡើយ ប៉ុន្តែត្រូវថ្វាយជីវិត របស់យើងទាំងស្រុងទុកជាតង្វាយ ដើម្បីបម្រើព្រះជាម្ចាស់ វិញ។ ការថ្វាយនេះ គឺជាការថ្វាយរូបកាយទាំងមូល។ ហើយការថ្វាយបែបនេះ តែងតែមានការលះបង់ ដោយសារវានាំឲ្យយើងកាត់ចិត្តចេញពីជីវិតខ្លួនឯង។ នេះហើយគឺជាការថ្វាយដ៏ពិត។*

*ការថ្វាយប្រភេទនេះនាំមកនូវព្រះគុណដល់អ្នកដទៃ និងនាំឲ្យមានការផ្លាស់ប្រែនៅក្នុងខ្លួនយើងផងដែរ។ បើយើងថ្វាយ នោះយើងនឹងទទួលនូវអ្វីដែលពិសេសជាងអ្នក ដែលមិនថ្វាយ។*

លោក ឆាលស៍ រីងម៉ា (Charles Rignma)
ដកស្រង់ចេញពីសៀវភៅ *Wash the Feet of the World with Mother Teresa*

# ការប្រើប្រាស់ពេលវេលា



ព្រះជាម្ចាស់បានប្រគល់ពេលវេលា ១៦៨ ម៉ោង រៀងរាល់សប្តាហ៍ដល់គ្រប់មនុស្សប្រុសស្រី។ តើលោកអ្នកបានចំណាយពេលយ៉ាងឆ្លាតវៃដែរ ឬទេ ឬក៏គ្រាន់តែចំណាយពេលដោយឥតប្រយោជន៍? ការចំណាយពេលយ៉ាង

ឆ្លាតវៃអាចនាំមកនូវផលផ្លែដ៏ត្រចះត្រចង់។ របៀបនៃការប្រើប្រាស់ពេលវេលារបស់លោកអ្នកនឹងសឲ្យឃើញអំពីគុណតម្លៃដ៏ជាក់លាក់របស់លោកអ្នក។

៤. សូមអានកណ្ឌគម្ពីរ ម៉ាថាយ ៦:២៥-៣៤។

ក) តើការពីរយ៉ាងដែលព្រះជាម្ចាស់បានប្រាប់ឲ្យអ្នកជឿស្វែងរកនោះគឺជាអ្វី? (ខ៣៣)

ខ) តើលោកអ្នកគិតថា “នគរនៃព្រះ” មានអត្ថន័យយ៉ាងដូចម្ដេច?

គ) សូមឲ្យអត្ថន័យលើ “សេចក្ដីសុចរិតនៃព្រះ”។

ឃ) សូមសរសេរខ៣៣ ដោយប្រើពាក្យពេចន៍ និងការពណ៌នាផ្ទាល់ខ្លួនរបស់លោកអ្នកដោយបញ្ជាក់អំពី «នគរ និងសេចក្តីសុចរិតនៃព្រះ»។

៥. សូមអានកណ្ឌគម្ពីរ ១ធីម៉ូថេ ៣:៤-៥, ១២។ នៅក្នុងក្រឹត្យក្រមនៃគុណតម្លៃរបស់ព្រះជាម្ចាស់ តើមានការណាខ្លះដែលយើងគួរធ្វើមុននឹងយកចិត្តទុកដាក់លើក្រុមជំនុំរបស់ទ្រង់?

៦. តើយើងគួរធ្វើការយ៉ាងដូចម្តេច យោងតាមកណ្ឌគម្ពីរ ២ថែស្សាឡូនីច ៣:៧-៩?

៧. ចូរដាក់លេខរៀងនៃចំណុចនីមួយៗខាងក្រោមតាមលំដាប់លំដោយដែលជាអាទិភាពចម្បងក្នុងជីវិតរបស់លោកអ្នកនាពេលបច្ចុប្បន្ននេះ។ បន្ទាប់មកធ្វើវាម្តងទៀត តាមការដែលលោកអ្នកយល់ថា វានោះជាអាទិភាពចម្បងរបស់ព្រះជាម្ចាស់ដែលមានសម្រាប់ជីវិតរបស់លោកអ្នក។

| លេខ | **អាទិភាពរបស់លោកអ្នក     អាទិភាពរបស់ព្រះជាម្ចាស់** | លេខ |
|---|---|---|
| | ការងារ (ការជ្រើសរើសវិជ្ជាជីវៈ ឬក៏ការងារមួយរបស់លោកអ្នក) | |
| | ព្រះជាម្ចាស់ (ការបង្កើតទំនាក់ទំនងរបស់លោកអ្នកជាមួយនឹងទ្រង់) | |
| | សាលា (ការអភិវឌ្ឍចំណេះដឹងរបស់លោកអ្នក) | |
| | គ្រួសារ (សេចក្តីស្រឡាញ់ ការយកចិត្តទុកដាក់របស់លោកអ្នក និងការណែនាំពួកគេ) | |
| | ព័ន្ធកិច្ច (ការឈោងចាប់អ្នកដទៃទៀត និងការធ្វើបន្ទាល់) | |
| | ការចៃចូវ ឬអាពាហ៍ពិពាហ៍ | |
| | មិត្រភក្តិ | |
| | ការគ្រប់គ្រងទ្រព្យសម្បត្តិ | |
| | ការបម្រើអ្នកទ័លក្រ | |
| | ផ្សេងៗ (សកម្មភាពប្រចាំថ្ងៃ សកម្មភាពក្នុងសង្គម ទម្លាប់ប្រចាំថ្ងៃ និងការកម្សាន្តសប្បាយ) | |

៨. បន្ទាប់ពីពិចារណាពីអាទិភាពចម្បងរបស់ព្រះជាម្ចាស់រួចមក ប្រហែលជាលោកអ្នកចង់ផ្លាស់ប្តូរកាលវិភាគប្រចាំសប្តាហ៍របស់ខ្លួន ដើម្បីឲ្យកិច្ចការដែលលោកអ្នកធ្វើបានកើតឡើងព្រមគ្នាជាមួយនឹង អាទិភាពចម្បងរបស់ព្រះជាម្ចាស់ក្នុងជីវិត។ តើចំណុចណាខ្លះនៃ កាលវិភាគប្រចាំសប្តាហ៍របស់លោកអ្នកដែលលោកអ្នកគួរទទួលស្គាល់ ថា ត្រូវតែមានការផ្លាស់ប្តូរ?

លោកអ្នកគួរតែបន្តអធិស្ឋាន ហើយវាយតម្លៃទៅលើការចំណាយពេល ផ្ទាល់ខ្លួនបន្ថែមទៀត ដើម្បីឲ្យមានតុល្យភាពចំពោះសកម្មភាពផ្សេងគ្នាដែល ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យលោកអ្នកធ្វើ។

៩. សូមអានកណ្ឌគម្ពីរ អេភេសូរ ៥:១៥-២១។
តើសាវ័ក ប៉ុល បានមានប្រសាសន៍ពីការប្រើប្រាស់ពេលវេលាឲ្យមាន ប្រសិទ្ធភាពយ៉ាងដូចម្តេច? តើលោកអ្នកអាចអនុវត្តតាមការដាស់តឿន របស់សាវ័ក ប៉ុលយ៉ាងដូចម្តេច?

ខាងក្រោមនេះ គឺជាចំណុចគួរពិចារណាមួយចំនួនទាក់ទងនឹងរបៀបនៃការប្រើប្រាស់ពេលវេលាដែលប្រកបដោយប្រសិទ្ធភាព៖

- ការធ្វើគម្រោងដោយអធិស្ឋានយ៉ាងអស់ពីចិត្ត៖ ស្ដាប់ព្រះជាម្ចាស់។ បន្ទាប់មកសរសេរពីអាទិភាពនៃកិច្ចការដែលត្រូវបញ្ចប់តាមលំដាប់។
- ការជ្រើសរើសដែលពេញដោយការស្ដាប់បង្គាប់៖ ធ្វើតាមការដឹកនាំរបស់ព្រះជាម្ចាស់ដោយបំពេញកិច្ចការដែលសំខាន់ជាងគេជាមុនសិន។ សូមថ្វាយកិច្ចការដែលមិនទាន់បានបញ្ចប់ដល់ព្រះជាម្ចាស់ដោយជំនឿ។
- ការផ្ចង់ចិត្ត និងឧស្សាហ៍៖ សូមធ្វើកិច្ចការណាដែលលោកអ្នកបានជ្រើសរួចឲ្យអស់ពីចិត្ត។

# ការប្រើប្រាស់អំណោយទាន



ព្រះជាម្ចាស់បានតាក់តែង រូបរាង សូរសម្លេង លទ្ធភាព ចំណុចខ្លាំង ចំណុចខ្សោយ និងអត្តចរិតផ្សេងៗទៀត ក៏ដូចជាអំណោយទានខាងឯវិញ្ញាណដល់អ្នកជឿទាំងអស់ផងដែរ។ បុគ្គលម្នាក់ៗត្រូវមានចំណែកក្នុងរូបកាយរបស់ព្រះគ្រីស្ទ ដោយបង្ហាញអាកប្បកិរិយាដែលមានលក្ខណៈដូចទ្រង់ ហើយស្អាងអ្នកដទៃទៀតឡើងតាមរយៈការប្រើប្រាស់ធនធានដែលព្រះជាម្ចាស់បានប្រទានមកពួកគេនោះ។

១០. ចំណុចខ្លាំងបីយ៉ាងដែលសាវ័ក ពេត្រុស អាចសរសេរអំពីខ្លួនគាត់បាន គឺ ភាពឆេះឆួល ភាពជាអ្នកដឹកនាំ និងភាពប៉ិនប្រសព្វក្នុងការនិយាយ។ ឯចំណុចកម្សោយមួយរបស់គាត់គឺ ការធ្វើតាមតែសន្ទុះចិត្តដោយមិនអាចគ្រប់គ្រងបាន។ សូមសរសេរចំណុចខ្លាំងបីយ៉ាង និងចំណុចខ្សោយមួយរបស់លោកអ្នក។

១១. សូមអានកណ្ឌគម្ពីរ រ៉ូម ១២:៣-៨។

ក) តើអ្នកជឿម្នាក់គួរមានការយល់ឃើញបែបណាពីខ្លួនឯង និងពីអំណោយទានរបស់ខ្លួន? (ខ៣)

ខ) សូមសង្ខេបការបង្រៀនរបស់សាវ័ក ប៉ុល ស្ដីពីរបៀបដែលអ្នកជឿគួរតែប្រើប្រាស់អំណោយទានដែលព្រះជាម្ចាស់បានប្រទានដល់ពួកគេ។

១២. តើយើងគួរប្រើប្រាស់អំណោយទានដែលព្រះជាម្ចាស់បានប្រទានមកដល់យើងនោះយ៉ាងដូចម្ដេច? (១ពេត្រុស ៤:១០)

សូមជ្រើសរើសយកចំណុចខ្លាំង ឬក៏អំណោយទានណាមួយរបស់លោកអ្នក។ តើលោកអ្នកអាចប្រើចំណុចខ្លាំង ឬក៏អំណោយទាននោះដើម្បីបម្រើអ្នកដទៃទៀតបានយ៉ាងដូចម្ដេច?

## ការយកចិត្តទុកដាក់លើរូបកាយ



សូមថែរក្សារូបកាយរបស់លោកអ្នកដោយយកចិត្តទុកដាក់ ពីព្រោះរូបកាយនោះជាព្រះវិហារនៃព្រះវិញ្ញាណបរិសុទ្ធ។ នៅពេលដែលលោកអ្នកមានអាហារូបត្ថម្ភ ការសម្រាន្ត និងការហាត់ប្រាណឲ្យបានត្រឹមត្រូវ នោះលោកអ្នកនឹងមានអារម្មណ៍ថា ស្រួលខ្លួនជាងមុន។

១៣. សូមអានកណ្ឌគម្ពីរ ១កូរិនថូស ៦:១៩-២០។ តើការដែលថា លោកអ្នកគឺជាព្រះវិហារនៃព្រះវិញ្ញាណបរិសុទ្ធនោះមានន័យយ៉ាងដូចម្ដេច?

១៤. សូមអានកណ្ឌគម្ពីរ រ៉ូម ១២:១ និង ២កូរិនថូស ៧:១។ តើសាវ័ក ប៉ុល បានជំរុញឲ្យយើងរាល់គ្នាធ្វើយ៉ាងដូចម្តេចចំពោះរូបកាយរបស់យើង? ហេតុអ្វី?

១៥. តើសាវ័ក យ៉ូហាន មានបំណងប្រាថ្នាយ៉ាងណាទៀត ក្រៅតែពីមានទំនាក់ទំនងល្អខាងឯវិញ្ញាណ? (៣យ៉ូហាន ១:២)

១៦. សូមអធិស្ឋានជ្រើសរើសយកផ្នែកណាមួយដែលលោកអ្នកអាចបង្កើនការយកចិត្តទុកដាក់លើរូបកាយថែមទៀត ដោយយោងតាមចំណុចនីមួយៗខាងក្រោមនេះ។ តើការផ្លាស់ប្តូរបែបណាខ្លះដែលលោកអ្នកនឹងសម្រេចចិត្តធ្វើ?

រក្សាការទទួលទានឲ្យបានត្រឹមត្រូវ

ហាត់ប្រាណឲ្យបានទៀងទាត់

សម្រាកឲ្យបានគ្រប់គ្រាន់

ចៀសវាងពីទម្លាប់ដែលនាំឲ្យមានគ្រោះថ្នាក់

## ការប្រើប្រាស់ថវិកា



ព្រះយេស៊ូវបានប្រទាននូវជម្រើសដ៏ច្បាស់លាស់មួយដល់យើង៖ យើងអាចជ្រើសរើសបម្រើលុយ ឬក៏អាចជ្រើសរើសបម្រើព្រះជាម្ចាស់។ ដើម្បីប្រឆាំងទៅនឹងសេចក្ដីល្បួងក្នុងការជ្រើសរើសបម្រើលុយ ព្រះយេស៊ូវបានត្រាស់ហៅអ្នកដើរតាមទ្រង់ឲ្យចាត់ទុកការចែករំលែកប្រាក់កាសជារបៀបចម្បងក្នុងការថ្វាយបង្គំព្រះជាម្ចាស់ ហើយចាត់ទុកការជួយផ្គត់ផ្គង់ដល់អ្នកដទៃជាអាទិភាពបន្ទាប់។ ការជ្រើសរើសបម្រើលុយមានន័យថា បោះបង់ចោលការថ្វាយបង្គំព្រះជាម្ចាស់។ យើងមិនអាចបម្រើព្រះជាម្ចាស់ផង និងលុយផងបានទេ។

១៧. សូមពិចារណាទៅលើកណ្ឌគម្ពីរ ម៉ាថាយ ៦:២៤។ តាមការយល់ឃើញរបស់លោកអ្នក សូមគិតទៅមើលថា ហេតុអ្វីបានជាការបម្រើលុយប្រឆាំងគ្នាទៅនឹងការបម្រើព្រះជាម្ចាស់?

មិនថាបុគ្គលណាមានលុយច្រើន ឬតិចប៉ុណ្ណានោះទេ ចំណុចដែលសំខាន់នោះគឺថា តើគាត់អាចបម្រើលុយបានតាមរបៀបណាខ្លះ? តើគាត់អាចបញ្ឈប់ការបម្រើលុយនោះបានដោយរបៀបណា?

១៨. ហេតុអ្វីបានជាការមានឥរិយាបថត្រឹមត្រូវចំពោះប្រាក់មានសារៈសំខាន់? (១ធីម៉ូថេ ៦:១០)

“ *នៅក្នុងចំណោមពួកយើងរាល់គ្នាមានអ្នកខ្លះបានសម្លឹងមើលទៅអ្វីដែលគេកំពុងតែថ្វាយបង្គំ ហើយឃើញថា ក្នុងនោះក៏មានលុយមួយផងដែរ។*

*យើង និងអ្នកដែលទៅព្រះវិហារគ្រីស្ទបរិស័ទរាប់លាននាក់ផ្សេងទៀតតែងតែលើកឡើងថា ព្រះយេស៊ូវសង្គ្រោះយើង ប៉ុន្តែអាកប្បកិរិយារបស់យើងបង្ហាញឲ្យឃើញថា លុយជាអ្នកសង្គ្រោះយើងវិញ។ យើងរាល់គ្នានិយាយថា លុយផ្តល់ឲ្យមានអំណាច លុយបង្កើតឲ្យមានអំពើពុករលួយ ហើយលុយក៏អាចនិយាយស្តីបានដែរ។ វាដូចជាកាលដែលជនជាតិអ៊ីស្រាអែលនៅសម័យមុននាំគ្នារៀបចំធ្វើគោមាស ដើម្បីថ្វាយបង្គំអញ្ចឹង ប្រៀបបានដូចជាយើងបានចាត់ទុកលុយជាព្រះដែលមានកម្លាំង មានដៃ មានជើង ព្រមទាំងប្រាប់ខ្លួនឯងថា លុយអាចធ្វើការជាច្រើនឲ្យយើង។ ជាងនេះទៅទៀត យើងបានដាក់តម្កល់វានៅកន្លែងអាថ៌កំបាំងមួយ ហើយក៏បានដាក់ចិត្តដាក់កាយ ព្រមទាំងឲ្យវាមានអំណាចលើយើងក្នុងការផ្តល់នូវសន្តិភាព និងសេចក្តីមេត្តាករុណាផងដែរ។*

លោកស្រី អេលីសាបិត អូខនន័រ (Elizabeth O’Connor)
ដកស្រង់ចេញពីសៀវភៅ *Letters to Scattered Pilgrims*

១៩. ខគម្ពីរទាំងប្រាំខាងក្រោមនេះមានការជាប់ទាក់ទងគ្នាទៅនឹងការប្រើប្រាស់លុយ។ សូមផ្គូផ្គងឲ្យបានត្រឹមត្រូវតាមការបកស្រាយនីមួយៗ៖

| | | |
|---|---|---|
| ក) សុភាសិត ២០:១០ | ___ | ការរកចរិកាដើម្បីផ្គត់ផ្គង់អ្នកដទៃដោយចិត្តសប្បុរស |
| ខ) សុភាសិត ២២:៧ | ___ | ការព្រមានអំពីសេចក្តីលោភ និងការស្វែងរកអត្តសញ្ញាណនៅក្នុងវត្ថុដែលជាកម្មសិទ្ធិរបស់យើង |
| គ) លូកា ១២:១៥ | ___ | គ្រោះថ្នាក់នៃការខ្ចីលុយ និងការក្លាយទៅជាអ្នកជំពាក់បំណុល |
| ឃ) លូកា ១៦:១១ | ___ | ការសន្សំទំនុកចិត្តតាមរបៀបដែលយើងប្រើប្រាស់លុយ |
| ង) អេភេសូរ ៤:២៨ | ___ | ការព្រមានពីការកេងបន្លំអ្នកដទៃ |

២០. សូមអានកណ្ឌគម្ពីរ ២កូរិនថូស ៩។ តើគោលការណ៍នៃការផ្តល់ឲ្យដែលលោកអ្នកអាចរកឃើញនៅក្នុងខនីមួយៗខាងក្រោមនេះមានអ្វីខ្លះ?

ខ៦

ខ៧

ខ៨

ខ១២

ខ១៣

ខ១៥

ក) តើលោកអ្នកធ្លាប់ដែលបានទទួលអំណោយមួយពីនរណាម្នាក់ដែលគាត់ឲ្យដោយចិត្តទើសទាល់ដែរឬទេ? តើការនោះធ្វើឲ្យលោកអ្នកមានអារម្មណ៍យ៉ាងដូចម្ដេចដែរ?

ខ) តើលោកអ្នកគិតថា ព្រះជាម្ចាស់មានព្រះហឫទ័យយ៉ាងណា នៅពេលដែលយើងថ្វាយភាគតិច ឬក៏ស្ដាយនូវអ្វីដែលយើងបានថ្វាយដល់ទ្រង់?



មានអ្នកជឿជាច្រើនបានរកឃើញថា បើគេមានផែនការក្នុងការថ្វាយតង្វាយដ៏ទៀងទាត់ នោះជាការដែលត្រូវតាមបទគម្ពីរ និងជាការមួយដែលអាចធ្វើបានផងដែរ។ ផែនការនៃការថ្វាយគឺជាការកំណត់ឲ្យមានភាពច្បាស់លាស់ណាមួយ ព្រមទាំងជៀសវាងការភាន់ច្រឡំ ភាពព្រងើយកន្តើយ ឬការមិនយកចិត្តទុកដាក់ក្នុងការថ្វាយ។ សព្វថ្ងៃនេះ យើងឃើញថា មានមនុស្សជាច្រើនកំពុងតែមានតម្រូវការលើពេលវេលា និងប្រាក់កាសរបស់លោកអ្នក ដូច្នេះហើយគម្រោងការក្នុងការផ្តល់ឲ្យនឹងជួយលោកអ្នកក្នុងការថ្វាយកិត្តិនាមដល់ព្រះអម្ចាស់តាមរយៈទ្រព្យសម្បត្តិ និងពេលវេលារបស់លោកអ្នក។ គម្រោងការរបស់លោកអ្នកប្រហែលជាអាចរួមបញ្ចូលចំណុចខាងក្រោមទាំងនេះ៖

១. សូមចងចាំថា លោកអ្នកថ្វាយដល់ព្រះជាម្ចាស់។ អំណោយរបស់លោកអ្នកអាចផ្តល់ជាប្រយោជន៍ដល់អ្នកដទៃ ប៉ុន្តែវាជាចំណែកនៃការថ្វាយបង្គំព្រះជាម្ចាស់ដ៏ចម្បង។ ហេតុដូច្នេះហើយ លោកអ្នកត្រូវតែឲ្យដោយអំណរ ពីព្រោះអ្វីៗទាំងអស់ដែលលោកអ្នកបានទទួលគឺសុទ្ធតែមកពីព្រះជាម្ចាស់។

២. សូមអធិស្ឋានពីការសម្រេចចិត្តពីចំនួនភាគរយនៃចំណូលដែលលោកអ្នកនឹងត្រូវថ្វាយទៅព្រះជាម្ចាស់វិញ។

៣. សូមញែកចំណែករបស់ព្រះជាម្ចាស់ទុកជាមុន នៅពេលណាដែលលោកអ្នកទទួលបានប្រាក់កាស។ សូមទុកវាដោយឡែកសម្រាប់ប្រើប្រាស់នៅពេលដែលទ្រង់ដឹកនាំឲ្យប្រើ ហើយលោកអ្នកមិនត្រូវប្រើប្រាស់សម្រាប់គោលបំណងណាផ្សេងទៀតឡើយ។

៤. សូមអធិស្ឋានពីការបែងចែកលុយរបស់ព្រះជាម្ចាស់តាមបំណង ព្រះហឫទ័យរបស់ទ្រង់។ វាគឺជាការល្អ ណាស់ក្នុង ការធ្វើកិច្ចការនេះឲ្យ បានទៀងពេលវេលាដូចជា រាល់សប្ដាហ៍ ឬក៏រៀងរាល់ខែ។

សូមបង្កើនការផ្ដល់ឲ្យរបស់លោកអ្នក ស្របពេលដែលព្រះជាម្ចាស់បាន បង្កើនជំនឿរបស់លោកអ្នក និងពេលដែលទ្រង់បានចាក់ព្រះពរបន្ថែមទៀត លើលោកអ្នក។ នៅពេលដែលលោកអ្នកថ្វាយសិទ្ធិក្នុងការគ្រប់គ្រងធនធាន របស់ខ្លួនដល់ព្រះជាម្ចាស់ នោះទ្រង់នឹងប្រទានធនធានខាងវិញ្ញាណរបស់ ទ្រង់ដល់លោកអ្នកវិញជាមិនខាន ដ្បិតទ្រង់បានសម្រេចព្រះទ័យភ្ជាប់អង្គទ្រង់ ជាមួយនឹងគោលការណ៍នេះរួចហើយ។ (លូកា ១៦:៩-១២ និង ភីលីព ៤:១៧)

អ្នកដែលថ្វាយប្រាក់កាសរបស់ខ្លួនដល់ព្រះជាម្ចាស់ នោះមានន័យថា គាត់ កំពុងតែថ្វាយជីវិត ពេលវេលា ភាពឆ្លាតវៃ និងកម្លាំងរបស់គាត់ដល់ព្រះជាម្ចាស់។ តែចំពោះបុគ្គលដែលមិនមានភាពប្រាកដប្រជាក្នុងការថ្វាយប្រាក់កាសរបស់ ខ្លួនដល់ព្រះជាម្ចាស់នោះមានន័យថា គាត់មិនទាន់បានប្ដេជ្ញាចិត្តយ៉ាងពេញ ទំហឹងចំពោះការចុះចូលនៅក្រោមអំណាចរបស់ព្រះជាម្ចាស់នៅឡើយទេ។

សូមប្រើចន្លោះតារាងខាងក្រោម ដើម្បីសរសេរពីគម្រោងនៃការផ្តល់ឲ្យរបស់លោកអ្នក។

| គម្រោងនៃការផ្តល់ឲ្យរបស់ខ្ញុំ | |
|---|---|
| ហេតុដែលខ្ញុំគ្រោងផ្តល់ឲ្យ៖ | |
| ទឹកចិត្តរបស់ខ្ញុំក្នុងការផ្តល់ឲ្យ៖ | |
| អ្នក ឬកន្លែងដែលខ្ញុំគ្រោងនឹងផ្តល់ឲ្យ៖ | |
| ចំនួនដែលខ្ញុំនឹងផ្តល់ឲ្យ៖ | |
| ពេលដែលខ្ញុំគ្រោងនឹងផ្តល់ឲ្យ៖ | |

> *តើសំណួរថា "ខ្ញុំគួរផ្តល់ឲ្យប៉ុណ្ណា" ជាសំណួរមិនត្រឹមត្រូវឬ? តើលោកអ្នកដែលធ្លាប់ទូលសួរព្រះជាម្ចាស់ពីចំណូល ឬក៏ពេលវេលាប៉ុណ្ណាដែលលោកអ្នកគួរតែថ្វាយទៅទ្រង់វិញដែរឬទេ? ប្រហែលជាយើងសួរសំណួរដែលមិនត្រឹមត្រូវហើយមើលទៅ។ យើងគួរតែសួរថា តើយើងគួរទុកសម្រាប់ខ្លួនយើងប៉ុណ្ណាពីចំនួនដែលទ្រង់បានប្រទានឲ្យ?*

២១. សូមអានកណ្ឌគម្ពីរ ម៉ាកុស ១២:៤១-៤៤។ តើគោលការណ៍ដែលព្រះយេស៊ូវព្យាយាមយកមកបង្រៀនដល់សិស្សរបស់ទ្រង់អំពីគំរូរបស់ស្ត្រីមេម៉ាយនោះគឺជាអ្វី?

តើតាមរយៈគំរូរបស់ស្ត្រីនោះ ព្រះជាម្ចាស់បានមានបន្ទូលអ្វីមកកាន់លោកអ្នកផ្ទាល់?

២២. សូមសញ្ជឹងគិតលើសេចក្ដីបង្រៀនរបស់ព្រះយេស៊ូវចេញពីកណ្ឌគម្ពីរម៉ាថាយ ៦:១៩-២១។

ក) តើគ្រោះថ្នាក់ និងការប្រថុយប្រថានមួយចំនួនដែលគំរាមកំហែងទ្រព្យសម្បត្តិខាងឯលោកីយ៍របស់យើងមានអ្វីខ្លះ? (ខ១៩)

ខ) តើលោកអ្នកចាត់ទុកអ្វីខ្លះថាជាទ្រព្យសម្បត្តិនៅស្ថានសួគ៌? (ខ២០)

គ) នៅពេលដែលព្រះយេស៊ូវមានបន្ទូលថា “កុំឲ្យប្រមូលទ្រព្យសម្បត្តិទុក” តើលោកអ្នកគិតថា ទ្រង់កំពុងតែទាស់នឹងនិន្នាការនៃការសន្សំប្រាក់កាស ការធ្វើវិនិយោគទុន ឬគម្រោងនៃការចូលនិវត្តន៍ឬ? (ខ១៩-២០) សូមពន្យល់៖

ឃ) សូមពន្យល់ពីសេចក្ដីពិតដែលមាននៅក្នុងខ២១ តាមការយល់ឃើញរបស់លោកអ្នក។

## ផ្អាកបន្តិចដើម្បីអធិស្ឋាន

សូមបញ្ចប់ការសិក្សារបស់លោកអ្នកដោយការអធិស្ឋាន។ ចូរអរព្រះគុណព្រះជាម្ចាស់ដែលបានប្រទានអ្វីៗដល់លោកអ្នក។ សូមពិភាក្សាជាមួយនឹងទ្រង់អំពីចំណុចខ្សោយ និងចំណុចខ្លាំងស្តីពីការគ្រប់គ្រងទៅលើអ្វីដែលទ្រង់បានប្រទានឲ្យលោកអ្នកដូចជាៈ មនុស្សជាតិ ពេលវេលា កម្លាំងកំហែង អំណោយទាន ប្រាក់កាស សុខភាព និងទំនួលខុសត្រូវជាដើម។ល។ ហើយសូមទូលថ្វាយទ្រង់ថា តើលោកអ្នកកំពុងតែស្តាប់បង្គាប់តាមបញ្ញត្តិរបស់ទ្រង់ដែលថា ចូរស្វែងរកនគរ សេចក្តីសុចរិត និងទ្រព្យសម្បត្តិរបស់ទ្រង់នៅឯស្ថានសួគ៌ជាមុនដល់កម្រិតណាហើយ?

# សំណេរីខគម្ពីរមួយសម្រាប់ការ សញ្ជឹងគិត និងការទន្ទេញចាំមាត់



ម៉ាថាយ ៦:១៩-២១

“កុំឲ្យប្រមូលទ្រព្យសម្បត្តិ ទុកសំរាប់ខ្លួន នៅផែនដី ជាកន្លែងដែលមានកន្លាត និងច្រែះស៊ីបំផ្លាញ ហើយចោរទំលុះប្លន់នោះឡើយ ត្រូវប្រមូល ទ្រព្យសម្បត្តិ ទុកសំរាប់ខ្លួន នៅឯស្ថានសួគ៌វិញ ដែលជាកន្លែងគ្មានកន្លាត ឬច្រែះស៊ីបំផ្លាញឡើយ ក៏គ្មានចោរទំលុះ ឬប្លន់ផង ពីព្រោះសម្បត្តិទ្រព្យរបស់អ្នកស្ថិតនៅកន្លែងណា នោះចិត្តអ្នកក៏នឹងនៅកន្លែងនោះដែរ»។

ម៉ាថាយ ៦:១៩-២១

# សៀវភៅកំណត់ហេតុរបស់ខ្ញុំ

សូមសរសេរកំណត់ត្រាមួយក្នុងនាមលោកអ្នកជាអ្នកថ្វាយបង្គំព្រះជាម្ចាស់ មិនមែនថ្វាយបង្គំលុយ ស្តីអំពីរបៀបដែលលោកអ្នកបានចម្រើនឡើងក្នុងការផ្តល់ឲ្យ ស្របពេលដែលលោកអ្នកកំពុងរស់នៅក្នុងសម័យសម្ភារៈនិយមនេះ។

# ចំណុចគួរចងចាំ

សូមពិនិត្យប្រធានបទបន្ទាប់បន្សំនៅក្នុងជំពូកនេះឡើងវិញ ហើយយកវាមកធ្វើជាគម្រោងមេរៀន ដើម្បីសង្ខេបជំពូកនេះដោយគំនិតលោកអ្នកផ្ទាល់។

# ការចូលឲ្យបានស៊ីជម្រៅ

តើលោកអ្នករាប់ខ្លួនថា លោកអ្នកគឺជាអ្នករ៉ាប់រង ឬក៏ជាម្ចាស់នៅលើជីវិត ពេលវេលា ទ្រព្យសម្បត្តិ និងរូបកាយរបស់លោកអ្នកឬ?

តើការធ្វើជាអ្នករ៉ាប់រង និងការធ្វើជាម្ចាស់មានលក្ខណៈខុសគ្នាយ៉ាងដូចម្តេច តាមយោបល់របស់លោកអ្នក?

តើចម្លើយរបស់លោកអ្នកបានជះឥទ្ធិពលលើការរស់នៅជាប្រចាំថ្ងៃរបស់លោកអ្នកយ៉ាងដូចម្តេច?

ជំពូកទី

# ៣

# ការជួយអ្នកដទៃ ស្វែងរកព្រះគ្រីស្ទ

ព្រះជាម្ចាស់មានព្រះហឫទ័យចង់ឃើញមនុស្សទាំងអស់ឱបក្រសោបព្រះគ្រីស្ទ ហើយទទួលយកសេចក្តីសង្គ្រោះតាមរយៈទ្រង់យ៉ាងខ្លាំងបំផុត។ ហេតុដូច្នេះហើយបានជាព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យបុត្រាបុត្រីរបស់ទ្រង់ធ្វើជាដៃគូជាមួយនឹងទ្រង់ ដើម្បីប្រាប់អ្នកដែលពួកគេស្គាល់ពីដំណឹងល្អរបស់ព្រះគ្រីស្ទ។ ព្រះជាម្ចាស់បានដាក់យើងឲ្យរស់នៅកន្លែងណាមួយ ដើម្បីឲ្យយើងនាំមិត្រភក្តិ និងអ្នកដែលនៅជុំវិញយើងឲ្យស្គាល់ព្រះជាម្ចាស់ ព្រោះទ្រង់ស្រឡាញ់ពួកគេ។ យើងមានភាពងាយស្រួលនឹងធ្វើដូច្នេះបាន ព្រោះយើងស្គាល់ពីប្រពៃណីរបស់ពួកគេ ហើយពួកគេក៏ស្គាល់យើងផងដែរ។ ហើយពាក្យសម្តី និងទង្វើរបស់យើងអាចនាំពួកគេឲ្យស្គាល់ព្រះជាម្ចាស់បាន។

“ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជំរះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះ ដោយសារទ្រង់វិញ” (យ៉ូហាន ៣:១៧)

# ការធ្វើជាដៃគូជាមួយព្រះជាម្ចាស់



១. តើគម្រោង និងបំណងព្រះហឫទ័យដ៏ចម្បងបំផុតរបស់ព្រះជាម្ចាស់ចំពោះមនុស្សលោកគឺជាអ្វី? (អេភេសូរ ៣:១-១០)

២. តើព្រះជាម្ចាស់ចាត់បញ្ជូនព្រះយេស៊ូវមកផែនដីនេះក្នុងគោលបំណងអ្វី?
ម៉ាកុស ១០:៤៥

លូកា ១៩:១០

យ៉ូហាន ១០:១០-១១

៣. យោងតាមសេចក្ដីអធិស្ឋានរបស់ព្រះយេស៊ូវមុននឹងទ្រង់យាងទៅឯឈើឆ្កាង តើទ្រង់បានពណ៌នាអំពីការរួមចំណែករបស់អ្នកដើរតាមទ្រង់យ៉ាងដូចម្ដេចខ្លះ ដើម្បីបំពេញបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដល់អស់អ្នកដែលមិនទាន់ស្គាល់ព្រះគ្រីស្ទនៅឡើយនោះ? (យ៉ូហាន ១៧:១៥-២៣)

៤. ហេតុអ្វីបានជាការផ្សាយដំណឹងពីព្រះគ្រីស្ទដល់អ្នកផ្សេងទៀតមានសារៈសំខាន់ខ្លាំងម្ល៉េះ? (យ៉ូហាន ១៤:៦, កិច្ចការ ៤:១២)

៥. នៅពេលដែលយើងចែកចាយពីព្រះគ្រីស្ទជាមួយអ្នកផ្សេងៗ គឺមានន័យថា យើងកំពុងតែចូលរួមនៅក្នុងព័ន្ធកិច្ចរបស់ព្រះជាម្ចាស់ក្នុងជីវិតរបស់ពួកគេ។ តើព្រះវិញ្ញាណបរិសុទ្ធកំពុងរៀបចំចិត្តមនុស្សឲ្យទទួលព្រះយេស៊ូវគ្រីស្ទដោយរបៀបណា? យ៉ូហាន ៣:៥-៨

យ៉ូហាន ១៦:៧-១១

១ថែស្សាឡូនីច ១:៤-៥

៦. សូមអានកណ្ឌគម្ពីរ ម៉ាថាយ ៤:១៩។ តើលោកអ្នកអាចរៀបចំខ្លួនយ៉ាងល្អបំផុត ដើម្បីផ្សាយដំណឹងល្អដល់អ្នកដទៃបានយ៉ាងដូចម្ដេច? សូមពន្យល់៖

## ការយកឈ្នះលើឧបសគ្គ



នៅពេលដែលយើងធ្វើជាដៃគូជាមួយនឹងព្រះជាម្ចាស់ ពួកយើងភាគច្រើនប្រឈមមុខទៅនឹងឧបសគ្គដែលនៅក្នុងចិត្តរបស់យើង។ ពួកយើងមួយចំនួនគ្រាន់តែភ្ជាប់ទំនាក់ទំនងជាមួយនឹងអ្នកជឿដូចគ្នាតែប៉ុណ្ណោះ ដោយសារតែភាពភ័យខ្លាច និងភាពមមាញឹករបស់យើងបានរារាំងយើងពីការបង្កើតទំនាក់ទំនងដែលប្រកបដោយភាពស្និទ្ធស្នាលជាមួយនឹងអ្នកមិនជឿផ្សេងៗ។ យើងក៏អាចមាន

ភាពភ័យខ្លាចក្នុងការចែកចាយពីបញ្ហានៃជីវិត អំពើបាប និងកម្សោយផ្ទាល់ខ្លួនរបស់យើងផងដែរ។ ព្រះគ្រីស្ទនឹងជួយយើងឲ្យមានជ័យជម្នះលើឧបសគ្គទាំងនេះ នៅពេលដែលយើងដើរតាមទ្រង់នៅក្នុងជីវិតដែលពេញដោយតម្រូវការ។

៧. សូមអានកណ្ឌគម្ពីរ ម៉ាថាយ ៩:១០-១៣។

ក) តើព្រះយេស៊ូវមានទំនាក់ទំនងជាមួយមនុស្សប្រភេទណាខ្លះ?

ខ) តើព្រះយេស៊ូវទាក់ទងជាមួយពួកគេយ៉ាងដូចម្ដេច?

គ) សូមសរសេរឈ្មោះមនុស្សមួយចំនួនដែលលោកអ្នកស្គាល់ (មិត្រភក្តិ សមាជិកគ្រួសារ មិត្តរួមថ្នាក់ អ្នកជិតខាង អ្នករួមការងារ និងអ្នកដែលស្គាល់ផ្សេងទៀតក្នុងសង្គម) ដែលមិនទាន់បានទទួលជឿព្រះគ្រីស្ទនៅឡើយ។

## ផ្អាកបន្តិចដើម្បីអធិស្ឋាន

ប្រសិនបើលោកអ្នកមានមិត្រភក្តិ ឬសមាជិកគ្រួសារតែពីរបីនាក់ដែលមិនទាន់ជឿ នោះចូរទូលសូមព្រះជាម្ចាស់ដឹកនាំលោកអ្នកឲ្យមានទំនាក់ទំនងជាមួយអ្នកផ្សេងៗថែមទៀតដែលមិនទាន់បានជឿព្រះយេស៊ូវ ដើម្បីឲ្យលោកអ្នកអាចផ្សាយដំណឹងល្អ ហើយបង្ហាញឲ្យពួកគេឃើញពីសេចក្តីស្រឡាញ់របស់ទ្រង់។

៨. សូមអានប្រស្នាអំពីស្រងែដែលព្រះយេស៊ូវមានបន្ទូលស្តីពីការរស់នៅក្នុងនាមជាសមាជិកគ្រួសាររបស់ទ្រង់នៅក្នុងចំណោមអស់អ្នកដែលមិនស្គាល់ព្រះគ្រីស្ទនៅឡើយ។ សូមលោកអ្នកគិតទៅមើលថា ហេតុអ្វីបានជាទ្រង់សព្វព្រះហឫទ័យឲ្យយើង (ដែលជាស្រូវ) បន្តលូតលាស់ជាមួយនឹងអស់អ្នកដែលមិនជឿ (ដែលជាស្រងែ)? (ម៉ាថាយ ១៣:២៤-៣០, ៣៦-៤២)*

---

* មកពី Jim Petersen និង Mike Shamy, *The Insider Workbook: Bringing the Kingdom of God Into Your Everyday World* (Colorado Springs, CO: NavPress, ឆ្នាំ២០០៣), ទំព័រ១៨។

៩. ស្របពេលដែលលោកអ្នករស់នៅ ដើម្បីថ្វាយបង្គំព្រះគ្រីស្ទក្នុងចំណោម អស់អ្នកមិនជឿ តើលោកអ្នកមានសេចក្ដីភ័យខ្លាចណាខ្លះ ក្នុងចំណោម សេចក្ដីភ័យខ្លាចខាងក្រោមនេះ?

- ខ្លាចគេបដិសេធ
- ខ្លាចគេឃើញពីទ្រឹស្ដីដែលមិនជាក់លាក់លើការផ្សាយដំណឹងល្អរបស់ខ្លួន
- ខ្លាចគេឃើញអារម្មណ៍ផ្ទាល់របស់លោកអ្នក
- ខ្លាចគេឃើញពីគុណវិបត្តិ ឬពីជីវិតខាងឯវិញ្ញាណផ្ទាល់ខ្លួន
- ការនិយាយចាកប្រធាន
- ខ្លាចគេអន់ចិត្ត ឬស្អប់
- ខ្លាចបាត់បង់ចំណងមិត្តភាព
- ខ្លាចបរាជ័យ
- ខ្លាចបន្ថែមភាពស្មុគស្មាញដល់ជីវិតដ៏មមាញឹករបស់ខ្លួន
- ខ្លាចអ្នកមិនជឿជះឥទ្ធិពលអវិជ្ជមានលើគ្រួសារលោកអ្នក
- ខ្លាចត្រាប់តាមទង្វើមិនល្អរបស់អ្នកមិនជឿ
- ខ្លាចរស់នៅក្រៅភាពសុខសាន្ដ
- ខ្លាចអ្នកជឿផ្សេងទៀតមិនពេញចិត្ត
- ការភ័យខ្លាចផ្សេងទៀត?______________________________*

១០. តើលោកអ្នកបានទទួលការលើកទឹកចិត្តត្រង់ចំណុចណាខ្លះចេញពី គំរូរបស់សាវ័ក ប៉ុល ដែលគាត់បានបើកចំហចិត្តចែកចាយពី រឿងទុក្ខលំបាករបស់គាត់ដល់ក្រុមជំនុំកូរិនថូស? (១កូរិនថូស ២:១-៥, ២កូរិនថូស ៤:៧-៩, ១២:៩-១១)

---

* មកពី Jim Petersen និង Mike Shamy, ទំព័រ៣២-៣៣។

# ការរស់នៅក្នុងចំណោមអ្នកមិនជឿ



១១. ដោយសារព្រះជាម្ចាស់កំពុងតែបំពេញព្រះហឫទ័យរបស់ទ្រង់តាមរយៈយើង ដូច្នេះតើយើងគួររស់នៅបែបណា ដើម្បីបង្ហាញពីព្រះគ្រីស្ទ ហើយទាក់ទាញមនុស្សឲ្យជឿលើទ្រង់?
(ភីលីព ២:១៣-១៦)

១២. តើមានសេចក្តីណែនាំណាខ្លះដែលលោកអ្នកអាចយកមកអនុវត្តបាន ដើម្បីឲ្យលោកអ្នកមានទំនាក់ទំនងល្អជាមួយនឹងអ្នកផ្សេងៗយោងតាមខគម្ពីរខាងក្រោមនេះ?
ម៉ាថាយ ៥:១៣-១៦

ម៉ាថាយ ៥:៤៦-៤៧

លូកា ៦:២៧-៣៦

សកម្មភាពដ៏សាមញ្ញមួយនៃការធ្វើគារវកិច្ចចំពោះមនុស្សឲ្យចំឈ្មោះរបស់ពួកគេ អាចបង្ហាញពីឱកាសក្នុងការបង្កើនទំនាក់ទំនងជាមួយពួកគេឲ្យបានកាន់តែស៊ីជម្រៅថែមទៀត។ សូមចងចាំពីឈ្មោះមនុស្សបីនាក់ដែលលោកអ្នកមិនស្គាល់ រួចសរសេរឈ្មោះអ្នកទាំងនោះនៅចន្លោះខាងក្រោម។ បន្ទាប់មកចាប់ផ្តើមរាប់អានសួរសុខទុក្ខអ្នកទាំងនោះនៅសប្តាហ៍ក្រោយៗទៀត។ សូមសរសេរពីអ្វីៗដែលកើតមានឡើង រួចមកពិនិត្យរកវិធីតូចតាចមួយចំនួនដូចជាការជូនផ្លែឈើនំចំណី សកម្មភាពសប្បុរសណាមួយ ឬការស្តាប់ពួកគេដោយយកចិត្តទុកដាក់ ដើម្បីពង្រឹងទំនាក់ទំនងជាមួយពួកគេ។*

* មកពី Jim Petersen និង Mike Shamy, ទំព័រ៦០។

១៣. អ្នកមិនជឿបានទទួលស្គាល់គ្រីស្ទបរិស័ទដើមដំបូងថា ជាអ្នកដើរតាមព្រះគ្រីស្ទបានដោយសារតែលក្ខណសម្បត្តិដ៏ល្អនៃសេចក្ដីស្រឡាញ់ និងសកម្មភាពនៃការបម្រើរបស់ពួកគេ។ សូមសង្ខេបចំណុចចម្បងនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១៣:១-៣ ដោយគំនិតរបស់លោកអ្នកផ្ទាល់។



១៤. សូមពិចារណាពីមធ្យោបាយជាក់ស្ដែងមួយចំនួនដែលលោកអ្នកអាចប្រើប្រាស់ ដើម្បីគ្រាប់តាមភាពជាអ្នកបម្រើរបស់ព្រះគ្រីស្ទ ដោយបម្រើអ្នកនៅជុំវិញខ្លួន។ នៅពេលដែលលោកអ្នកអានគំរូនីមួយៗនៃការបម្រើដែលស្របតាមព្រះគម្ពីរខាងក្រោមនេះ សូមសរសេរឈ្មោះរបស់អស់អ្នកមិនជឿដែលលោកអ្នកអាចបម្រើតាមរបៀបហ្នឹងបាន។

- ផ្ដល់ពេលវេលារបស់លោកអ្នក
- ផ្ដល់ការស្វាគមន៍យ៉ាងកក់ក្ដៅ
- ស្ដាប់ដោយយកចិត្តទុកដាក់
- ចូលរួមសុខរួមទុក្ខជាមួយនឹងពួកគេ

- បង្ហាញសេចក្ដីមេត្តាករុណាជាជាងការថ្កោលទោស
- និយាយការពិតដោយសេចក្ដីស្រឡាញ់
- រក្សាពាក្យសន្យារបស់លោកអ្នក
- ទប់កំហឹងរបស់លោកអ្នក
- ត្រូវចេះសុំទោស
- ត្រូវមានចិត្តសប្បុរស
- ប្រព្រឹត្តចំពោះខ្មាំងសត្រូវដោយក្ដីស្រឡាញ់
- ផ្សេងៗ? ________________*

១៥. នៅសម័យរបស់ព្រះយេស៊ូវ មិនមែនមនុស្សគ្រប់គ្នាសុទ្ធតែបានទទួលទ្រង់នោះឡើយ ហេតុដូច្នេះហើយសូមកុំឲ្យភ្ញាក់ផ្អើល ប្រសិនបើមាននរណាម្នាក់មិនបានទទួលព្រះយេស៊ូវគ្រីស្ទតាមរយៈជីវិតនៃការរស់នៅដែលប្រៀបបានដូចជា "ក្លិនក្រអូប" ឬក៏ពាក្យសម្ដីរបស់លោកអ្នកដែលពោរពេញដោយសេចក្ដីពិតនោះឡើយ។ ហេតុអ្វីបានជាមានមនុស្សមួយចំនួនអាក់អន់ចិត្ត ឬប្រឆាំងនឹងការផ្សាយដំណឹងល្អពីព្រះគ្រីស្ទដល់ពួកគេ? (២កូរិនថូស ២:១៤-១៧)

* មកពី Jim Petersen និង Mike Shamy, ទំព័រ៦២។

១៦. យោងតាមខគម្ពីរខាងក្រោម តើលោកអ្នកអាចអធិស្ឋានពីអ្វីខ្លះសម្រាប់អស់អ្នកដែលមិនទាន់ជឿលើព្រះគ្រីស្ទនៅឡើយ?

យ៉ូហាន ៦:៤៤

យ៉ូហាន ១៦:៨-៩

១ធីម៉ូថេ ២:១-៤

ព្រះយេស៊ូវយល់យ៉ាងច្បាស់ពីតម្រូវការរបស់មនុស្សម្នាក់ៗ ហើយទ្រង់បានមានបន្ទូលទាក់ទងទៅនឹងកង្វល់របស់អស់អ្នកដែលទ្រង់បានជួប។ តម្រូវការដ៏ធំជាងគេបំផុតរបស់មនុស្សដែលមិនទាន់ជឿព្រះគ្រីស្ទនោះគឺ ពួកគេត្រូវតែទទួលយកទ្រង់ធ្វើជាព្រះសង្គ្រោះ និងជាព្រះអម្ចាស់។ ប៉ុន្តែចំពោះមនុស្សដែលមិនទាន់ជឿព្រះគ្រីស្ទនោះប្រហែលជាគិតថា ពួកគេមានតម្រូវការផ្សេងៗទៀតជាច្រើនដែលពួកគេគួរតែទទួលមុនពេលដែលពួកគេពិចារណាទទួលយកព្រះគ្រីស្ទជាព្រះសង្គ្រោះ។ ប្រហែលជាលោកអ្នកត្រូវបំពេញតម្រូវការ “ខាងឯសាច់ឈាម” របស់ពួកគេជាមុនសិន ទើបលោកអ្នកអាចបំពេញតម្រូវការ “ខាងឯវិញ្ញាណ” របស់ពួកគេបាន។ ជាទូទៅមនុស្សចង់ដឹងថា លោកអ្នកខ្វល់ពីពួកគេច្រើនប៉ុណ្ណាមុននឹងពួកគេខ្វល់ថា លោកអ្នកចេះដឹងប៉ុណ្ណានោះ។

# ការពិភាក្សាអំពីដំណឹងល្អ



១៧. តើមានសេចក្តីណែនាំណាខ្លះពីព្រះគម្ពីរ ដែលយើងអាចត្រាប់តាម ដើម្បីឲ្យយើងមានភាពងាយស្រួលចែកចាយអំពីជំនឿរបស់យើងនៅក្នុងព្រះគ្រីស្ទជាមួយនឹងអ្នកផ្សេងៗ?

កូល៉ុស ៤:៥-៦

២ធីម៉ូថេ ២:២៣-២៦

១ពេត្រុស ៣:១៥

ខាងក្រោមនេះ គឺជាសេចក្តីណែនាំបន្ថែមមួយចំនួនដែលលោកអ្នកអាចប្រើប្រាស់ ដើម្បីឲ្យមានឱកាសផ្សាយដំណឹងល្អជាមួយមនុស្សផ្សេងៗបាន៖

- និយាយអំពីបញ្ហាទូទៅដែលមនុស្សគ្រប់គ្នាជួបប្រទះ។
- និយាយអំពីសម្រស់ និងអាថ៌កំបាំងរបស់ធម្មជាតិ។
- សួរសំណួរបញ្ចេញមតិមួយចំនួនដែលអាចបង្កើននូវការបរិយាយដោយសារសំណួរបែបនេះអាចពង្រឹងទំនាក់ទំនង។
- សូមស្តាប់ពីអ្វីដែលអ្នកផ្សេងទៀតកំពុងចែកចាយដោយយកចិត្តទុកដាក់។
- នៅពេលដែលលោកអ្នកឆ្លើយតបនឹងអ្វីដែលគេបានរៀបរាប់ ត្រូវដឹងថា ពួកគេប្រហែលមិនធ្លាប់ជួបប្រទះពាក្យខ្លះនៅក្នុងព្រះគម្ពីរនោះទេ ដូច្នេះសូមពន្យល់អត្ថន័យនៃពាក្យដែលលោកអ្នកប្រើផង។*

---

* មកពី Petersen និង Shamy, ទំព័រ៧២។

> *ចូរផ្សាយដំណឹងល្អរាល់ពេលវេលាដោយទង្វើរបស់លោកអ្នក ហើយប្រសិនបើចាំបាច់សូមប្រើពាក្យសម្ដីជាមួយផង។*

គេសន្មតថា នេះជាពាក្យសម្ដីរបស់លោក សេនថ៍ ហ្វ្រេនស៊ីស មកពីភូមិ អះស៊ីសស៊ីនៃប្រទេស អ៊ីតាលី (Attributed to Saint Francis of Assisi)

១៨. ហេតុអ្វីបានជាយើងត្រូវប្រើព្រះគម្ពីរឲ្យបានសមរម្យក្នុងការផ្សាយដំណឹងល្អ? ហើយត្រូវប្រើដោយរបៀបណា?

អេសាយ ៥៥:១១

២ធីម៉ូថេ ៣:១៥

ហេព្រើរ ៤:១២

១៩. ការប្រព្រឹត្តដោយក្ដីស្រឡាញ់ និងការបម្រើក្នុងបរិបទនៃទំនាក់ទំនងអាចជាចំណុចចាប់ផ្ដើមសម្រាប់លោកអ្នកក្នុងការពិភាក្សាជាមួយអ្នកដទៃអំពីជំនឿរបស់លោកអ្នក។ សំណួរបញ្ចេញមតិអាចជួយលោកអ្នកចែកចាយពីសេចក្ដីពិតខាងឯវិញ្ញាណនៅក្នុងការសន្ទនារបស់លោកអ្នកជាមួយអ្នកមិនជឿ។ សូមពិចារណាលើគំរូបីយ៉ាងនៃការចាប់ផ្ដើមសន្ទនាដែលមាននៅក្នុងតារាងខាងក្រោម។ គំរូទីមួយស្ដីពីនាង មាលា

ដែលជានិស្សិតមហាវិទ្យាល័យ។ ទីពីរ វិចិត្រដែលជាអ្នកជំនួញ ហើយទីបី វណ្ណៈដែលជាទាហាន។ តាមគំរូទាំងបីនេះ សូមបន្ថែមឈ្មោះមិត្រភក្តិរបស់លោកអ្នកពីរនាក់ទៀតដាក់ក្នុងតារាងជាអ្នកដែលលោកអ្នកចង់ចែកចាយដំណឹងល្អដល់ពួកគេ ព្រមទាំងសរសេរសំណួរសម្រាប់សន្ទនា និងទង្វើដែលពេញដោយក្តីស្រឡាញ់។

| បុគ្គល | សំណួរសម្រាប់ការសន្ទនា | ទង្វើដែលពេញដោយក្តីស្រឡាញ់ |
|---|---|---|
| នាង មាលា | តើចាប់តាំងពីប្អូនបានមកសិក្សានៅទីក្រុង អបិយជំនឿរបស់ប្អូនបានផ្លាស់ប្តូរយ៉ាងម៉េចដែរហើយ? | ជូននាងទៅប្រលង។ |
| បង វិចិត្រ | តើបងចង់ឃើញលទ្ធផលអ្វីខ្លះចេញពីអាជីវកម្មរបស់បង? | ជួយបោសសម្អាតទីធ្លាផ្ទះគាត់។ |
| ពូ វណ្ណៈ | ហេតុអ្វីបានជាពូគិតថា មានជម្លោះ និងបញ្ហាភេរវកម្មជាច្រើនលើពិភពលោកនាពេលបច្ចុប្បន្ននេះ? | ទៅសួរសុខទុក្ខទាហានក្នុងក្រុមជាមួយគាត់នៅឯមន្ទីរពេទ្យ។ |
| | | |
| | | |

២០. សូមសរសេរឈ្មោះសមាជិកគ្រួសារ ឬក៏មិត្រភក្តិណាម្នាក់ដែលជាអ្នកមិនជឿ ហើយលោកអ្នកបានជួបជាញឹកញាប់។ សូមបង្កើតសំណួរមួយចំនួនដែលអាចជួយលោកអ្នកឲ្យបង្វែរការសន្ទនាទូទៅរបស់លោកអ្នកឲ្យទៅជាការសន្ទនាពីដំណឹងល្អនៃព្រះគ្រីស្ទវិញ។ បន្ទាប់មក សូមរិះរកមធ្យោបាយជាក់ស្តែងមួយចំនួនដែលអាចបង្ហាញពីក្តីស្រឡាញ់របស់ព្រះជាម្ចាស់ទៅដល់បុគ្គលនោះ។

## ការចូលរួមក្នុងការកើតជាថ្មី



២១. សូមសង្ខេបចំណុចសំខាន់ៗស្តីពីដំណឹងល្អចេញពីកណ្ឌគម្ពីរ យ៉ូហាន ៣:១៦-១៨។

សូមត្រៀមខ្លួនជាស្រេច ដើម្បីចែកចាយអំពីព្រះគ្រីស្ទក្នុងគ្រប់កាលៈទេសៈទាំងអស់។ លោកអ្នកត្រូវដឹងពីចំណុចសំខាន់ៗនៃដំណឹងល្អ។ ត្រូវរៀបចំគម្រោង និងហាត់ពីរបៀបដែលលោកអ្នកត្រូវពន្យល់ពីព្រះគ្រីស្ទឲ្យបានច្បាស់លាស់ ហើយគួរឲ្យចាប់អារម្មណ៍។ បន្ទាប់មកសូមអធិស្ឋាន ហើយរកឱកាស ដើម្បីផ្សាយដំណឹងល្អ។

ក្រោយពីលោកអ្នកចែកចាយដំណឹងល្អរួចហើយ សូមសួរសំណួរដើម្បីជួយបុគ្គលម្នាក់នោះឲ្យបើកចិត្តទទួលព្រះគ្រីស្ទដែលមានដូចជា "តើអ្នកចង់ទទួលព្រះយេស៊ូវគ្រីស្ទទុកជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់របស់អ្នកឥឡូវនេះដែរឬទេ?" ប្រសិនបើគាត់ចង់ទទួល សូមឲ្យគាត់អធិស្ឋានយាងព្រះយេស៊ូវមកគង់នៅក្នុងជីវិតរបស់គាត់ទុកជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់របស់គាត់។

២២. នៅពេលដែលលោកអ្នកនាំបុគ្គលម្នាក់ឲ្យឈានជិតដល់ការសម្រេចចិត្តទទួលព្រះគ្រីស្ទ ជាការល្អប្រសិនបើលោកអ្នកប្រើខគម្ពីរដែលមានការបង្គាប់បញ្ជារ ដើម្បីបង្ហាញឲ្យគាត់ឃើញថា គាត់ត្រូវឆ្លើយតបចំពោះព្រះគ្រីស្ទដែលទ្រង់បានប្រទានសេចក្ដីសង្គ្រោះដល់គាត់ ស្របពេលដែលព្រះវិញ្ញាណបរិសុទ្ធកំពុងធ្វើការក្នុងចិត្តរបស់គាត់។ សូមជ្រើសរើសយកខគម្ពីរមួយក្នុងចំណោមខគម្ពីរខាងក្រោមនេះ ហើយពន្យល់ពីរបៀបដែលលោកអ្នកអាចប្រើប្រាស់ខគម្ពីរនោះឲ្យចំទៅនឹងស្ថានភាពនោះ។

យ៉ូហាន ១:១២

យ៉ូហាន ៣:១៦

យ៉ូហាន ៥:២៤

វិវរណៈ ៣:២០

២៣.តើមានអ្វីកើតឡើងរាល់ពេលណាដែលមានបុគ្គលម្នាក់ប្រែចិត្ត ហើយជឿទុកចិត្តលើព្រះគ្រីស្ទ? តើការនេះធ្វើឲ្យលោកអ្នកមានអារម្មណ៍យ៉ាងដូចម្តេច? (លូកា ១៥:៧)

## សំណេរខគម្ពីរមួយសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់



១ពេត្រុស ៣:១៥

ចូរឲ្យតាំងព្រះគ្រីស្ទឡើង ជាបរិសុទ្ធ នៅក្នុងចិត្តអ្នករាល់គ្នា ទុកជាព្រះអម្ចាស់ចុះ ហើយឲ្យប្រុងប្រៀបជានិច្ច ដោយសុភាព ហើយកោតខ្លាច ដើម្បីនឹងតបឆ្លើយដល់អ្នកណាដែលសួរពីហេតុនៃសេចក្តីសង្ឃឹមរបស់អ្នករាល់គ្នា

១ពេត្រុស ៣:១៥

# សៀវភៅកំណត់ហេតុរបស់ខ្ញុំ

មុនពេលដែលលោកអ្នកសម្រេចចិត្តជឿលើព្រះគ្រីស្ទ តើអ្នកដែលបានផ្សាយដំណឹងល្អដល់លោកអ្នកបានចែកចាយអ្វីខ្លះ ដើម្បីជួយឲ្យលោកអ្នកជឿលើទ្រង់? នៅពេលដែលលោកអ្នកកត់ពីហេតុការណ៍នេះចុះ សូមពណ៌នាពីអ្វីដែលជំរុញចិត្តលោកអ្នកឲ្យចែកចាយដំណឹងល្អពីព្រះគ្រីស្ទជាមួយអស់អ្នកដែលកំពុងតែស្វែងរកទ្រង់។

# ចំណុចគួរចងចាំ

សូមពិនិត្យប្រធានបទបន្ទាប់បន្សំនៅក្នុងជំពូកនេះឡើងវិញ ហើយយកវាមកធ្វើជាគម្រោងមេរៀន ដើម្បីសង្ខេបជំពូកនេះដោយគំនិតលោកអ្នកផ្ទាល់។

# ការចូលឲ្យបានស៊ីជម្រៅ

ការទទួលស្គាល់ថាខ្លួនមានបាប និងការមានបំណងចិត្តជឿលើព្រះគ្រីស្ទគឺមកពីព្រះជាម្ចាស់តែប៉ុណ្ណោះ។ ប៉ុន្តែព្រះជាម្ចាស់បានប្រទានអភ័យឯកសិទ្ធិដល់អស់អ្នកដែលដើរតាមព្រះយេស៊ូវ ឲ្យមានការរួមសហការជាមួយនឹងទ្រង់ដើម្បីជួយនាំអ្នកដទៃទៀតឲ្យមានជំនឿលើព្រះយេស៊ូវគ្រីស្ទ។

បុគ្គលដែលធ្លាប់ឮដំណឹងល្អហើយ តែមិនជឿតែងតែមានហេតុផលផ្សេងៗពីការមិនទទួលយកព្រះគ្រីស្ទ។ លោកអ្នកអាចរៀនដើម្បីឲ្យយល់ដឹងពីមូលហេតុដែលពួកគេមិនព្រមទទួលជឿព្រះគ្រីស្ទ ហើយអាចលើកយកចំណុចដែលត្រូវឆ្លើយតបតាមព្រះគម្ពីរមកបង្ហាញពួកគេដោយសមរម្យ។ ការធ្វើដូចនេះអាចជួយដល់អ្នកផ្សេងទៀតឲ្យឃើញយ៉ាងច្បាស់ពីតម្រូវការដ៏ចាំបាច់របស់ពួកគេក្នុងការទទួលយកព្រះយេស៊ូវគ្រីស្ទជាព្រះសង្គ្រោះ។ ខគម្ពីរខាងក្រោមនេះអាចជួយបង្ហាញលោកអ្នកឲ្យស្គាល់ពីមូលហេតុខ្លះៗដែលពួកគេមិនជឿ៖

| មូលហេតុដែលពួកគេមិនជឿ | ខគម្ពីរ |
|---|---|
| “ប្រសិនបើព្រះជាម្ចាស់មានពេញដោយអំណាចព្រះចេស្តា ហើយជាព្រះនៃសេចក្តីស្រឡាញ់នោះ ហេតុអ្វីបានជាទ្រង់អនុញ្ញាតឲ្យមានការអាក្រក់កើតឡើងនៅក្នុងលោកីយ៍នេះ? ហេតុអ្វីបានជាទ្រង់មិនបញ្ឈប់វា?” | ចោទិយកថា ៣០:១៩,<br>ម៉ាថាយ ១៣:២៤-៣០, រ៉ូម ៦:១៤ |
| “ខ្ញុំមិនសមនឹងទទួលសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ទេ”។ | អេភេសូរ ២:៣-៥,<br>១ពេត្រុស ២:៩-១០ |

| | |
|---|---|
| “គ្រីស្ទបរិស័ទគឺជាក្រុមមនុស្សដែលមិនមានការអត់ឱនឲ្យគ្នា ហើយបង្កឲ្យមានសង្គ្រាមជាច្រើនកើតឡើង នៅលើលោកនេះ”។ | យ៉ូហាន ១៣:៣៤-៣៥ |
| “ចុះអស់អ្នកដែលមិនធ្លាប់បានឮដំណឹងល្អនោះនឹងទៅជាយ៉ាងណា?” | ទំនុកដំកើង ១៩:១, ៩៧:៦, រ៉ូម ១:១៩-២០, កិច្ចការ ១៤:១៧ |
| “ចុះខគម្ពីរដែលមានភាពខុសប្រក្រតីនោះនឹងទៅជាយ៉ាងម៉េចដែរ?” | អេសាយ ៥៥:៨-៩, ២ធីម៉ូថេ ៣:១៦ |
| “ហេតុអ្វីបានជាអ្នកដែលមានចំណេះដឹងខ្ពង់ខ្ពស់ភាគច្រើនបដិសេធព្រះយេស៊ូវ?” | ដានីយ៉ែល ១២:១០, ១កូរិនថូស ២:១៤, ២ពេត្រុស ២:១៦-១៨ |
| “ចុះគ្រីស្ទបរិស័ទដែលមានពុតវិញ យ៉ាងម៉េចដែរ?” | យ៉ូប ៨:១៣, ម៉ាថាយ ៧:១, រ៉ូម ១៤:១២ |
| “ប្រសិនបើមនុស្សយើងខំធ្វើល្អ នោះគ្រប់គ្រាន់ហើយ ហើយយើងនឹងមានជីវិតល្អនៅជាតិក្រោយ”។ | យ៉ូហាន ៣:១៨, ៣៦, រ៉ូម ៣:២៣, ៦:២៣, ហេព្រើរ ២:៣, ៩:២៧ |
| “ប្រាកដណាស់ថា មិនមែនមានផ្លូវតែមួយគត់នោះទេ”។ | យ៉ូហាន ១១:២៥, ១៤:៦ |
| “តម្រូវឲ្យលះបង់ច្រើនពេក”។ | ទំនុកដំកើង ១១៦:១២, ម៉ាកុស ៨:៣៦, លូកា ១៨:២៩-៣០ |
| “ថ្ងៃណាមួយខ្ញុំប្រហែលជាក្លាយទៅជាអ្នកដើរតាមព្រះយេស៊ូវ”។ | សុភាសិត ២៧:១, អេសាយ ៥៥:៦, ម៉ាថាយ ២៤:៤៤, ២កូរិនថូស ៦:២ |
| “មានការជាច្រើននៅក្នុងព្រះគម្ពីរដែលខ្ញុំមិនយល់” ឬក៏ “ខ្ញុំត្រូវរង់ចាំរហូតទាល់តែខ្ញុំយល់បានច្រើនជាងហ្នឹងសិន”។ | ចោទិយកថា ២៩:២៩, រ៉ូម ១១:៣៣, ១កូរិនថូស ២:១៤, ១៣:១២ |
| “ខ្ញុំមិនមែនជាមនុស្សដែលអាក្រក់ប៉ុន្មានទេ”។ | លោកុប្បត្តិ ៦:៥, ១ពង្សាវតារក្សត្រ ៨:៤៦, សុភាសិត ២០:៩, អេសាយ ៥៣:៦, ៦៤:៦, រ៉ូម ៣:២៣, កាឡាទី ៣:២២, ១យ៉ូហាន ១:៨ |

| | |
|---|---|
| “ប្រហែលជាយើងនឹងទទួលបានឱកាសមួយទៀតនៅជាតិក្រោយ ដើម្បីទទួលជឿលើព្រះយេស៊ូវ”។ | លូកា ១៦:១៩-៣១, ហេព្រើរ ៩:២៧ |
| “បាបខ្ញុំធ្ងន់ណាស់ ព្រះជាម្ចាស់មិនអាចសង្គ្រោះខ្ញុំបានទេ ហើយទ្រង់ក៏មិនទទួលខ្ញុំដែរ”។ | ម៉ាកុស ២:១៧, យ៉ូហាន ៣:១៧, រ៉ូម ៥:៨, ១ធីម៉ូថេ ១:១៥ |

ជំពូកទី

# ៤

# ការចាក់គ្រឹះឲ្យរឹងមាំ

អភ័យឯកសិទ្ធិដែលយើងមានក្នុងការជួយអ្នកជឿថ្មីៗ ឲ្យពួកគេចាប់ផ្តើមចាក់គ្រឹះឲ្យរឹងមាំ ដើម្បីអាចដកពិសោធន៍ពីភាពពេញបរិបូរណ៍របស់ព្រះជាម្ចាស់ នោះពិតជាអស្ចារ្យមែន! ការលើកទឹកចិត្តឲ្យអ្នកដទៃផ្លាស់ប្រែខាងឯវិញ្ញាណ គឺជាទំនួលខុសត្រូវរបស់អស់អ្នកដែលដើរតាមព្រះយេស៊ូវ។ មានមនុស្សមួយចំនួនហៅការនេះថា ការចាក់គ្រឹះខាងជំនឿ ការប្រៀនប្រដៅ ការបង្កើតសិស្ស ឬការថែបំប៉ន បន្ទាប់ពីមានមនុស្សម្នាក់បានកើតជាថ្មីខាងឯវិញ្ញាណ។ ប៉ុន្តែទោះបីជាយើងប្រើឈ្មោះណាក៏ដោយ វានៅតែមានន័យដដែលថា ជាការធ្វើជាដៃគូជាមួយនឹងព្រះជាម្ចាស់ និងអ្នកជឿផ្សេងៗ ដើម្បីជួយអ្នកជឿថ្មីៗឲ្យមានភាពពេញវ័យខាងឯវិញ្ញាណ។ ទោះបីជាសមាគមន៍ទាំងមូលគួរសហការជួយគ្នាឲ្យពេញវ័យខាងឯវិញ្ញាណក៏ដោយ សម្រាប់សៀវភៅនេះវិញ យើងនឹងផ្តោតសំខាន់ទៅលើទំនាក់ទំនងម្នាក់ទល់ម្នាក់។ យ៉ាងហោចណាស់ក៏មានម្នាក់ត្រូវការជំនួយពីលោកអ្នកដែរ។

...ខ្ញុំលុតជង្គង់នៅចំពោះមុខព្រះវរបិតា...ដើម្បី...ឲ្យព្រះគ្រីស្ទបានសណ្ឋិតក្នុងចិត្តអ្នករាល់គ្នា ដោយសារសេចក្ដីជំនឿ ប្រយោជន៍ឲ្យអ្នករាល់គ្នាបានចាក់ឫស ហើយតាំងមាំមួនក្នុងសេចក្ដីស្រឡាញ់...ហើយឲ្យបានស្គាល់សេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទដ៏រកគិតមិនយល់ ប្រយោជន៍ឲ្យអ្នករាល់គ្នាបានពេញ ដល់គ្រប់ទាំងសេចក្ដីពោរពេញរបស់ផងព្រះ។ (អេភេសូរ ៣:១៤, ១៧, ១៩)

# ដូចម្ដេចដែលហៅថា ការចាក់គ្រឹះឲ្យរឹងមាំ?



១. សូមអានកណ្ឌគម្ពីរ ១ថែស្សាឡូនីច ២:៧-១២។

ក) តើសាវ័ក ប៉ុល បានពណ៌នាពីរបៀបដែលគាត់ខិតខំចាក់គ្រឹះដល់ក្រុមជំនុំថែស្សាឡូនីច ដើម្បីឲ្យទំនាក់ទំនងរបស់ពួកគេជាមួយនឹងព្រះយេស៊ូវកាន់តែរឹងមាំយ៉ាងដូចម្ដេច? (ខ៧-៨)

ខ) តើទំនាក់ទំនងរបស់សាវ័ក ប៉ុល ជាមួយពួកគេប្រៀបបានទៅនឹងអ្វី? (ខ៧, ៩, ១១)

គ) តើគាត់បានបង្ហាញពីគំរូ ហើយបានធ្វើយ៉ាងដូចម្ដេចខ្លះ ដើម្បីជួយឲ្យពួកគេរីកចម្រើនខាងវិញ្ញាណ?

ឃ) តើគោលដៅរបស់សាវ័ក ប៉ុល សម្រាប់កូនខាងវិញ្ញាណរបស់គាត់គឺជាអ្វី? (ខ១២)

ង) នៅក្នុងខ៨-១១ សាវ័ក ប៉ុល បានលើកឡើងថា គាត់មិនត្រឹមតែថាគាត់ស្រឡាញ់អស់អ្នកជឿនៅក្រុងថែស្សាឡូនីចប៉ុណ្ណោះទេ ប៉ុន្តែគាត់ថែមទាំងបង្ហាញពីសេចក្តីស្រឡាញ់ដល់ពួកគេទៀតផង។ ប្រសិនបើសាវ័ក ប៉ុល គ្រាន់តែបង្ហាត់បង្រៀនដល់ពួកគេ ហើយមិនបានបង្ហាញពីសេចក្តីស្រឡាញ់ដល់ពួកគេ តើលោកអ្នកគិតថាពួកគេនឹងទទួលបានអត្ថប្រយោជន៍អ្វីខ្លះ នៅពេលដែលពួកគេរៀនដើរតាមព្រះយេស៊ូវ?
(សូមមើលគន្លឹះជំនួយនៅចំណុច ការចូលឲ្យបានស៊ីជម្រៅ)

# ហេតុអ្វីបានជាត្រូវមាន ការចាក់គ្រឹះឲ្យរឹងមាំ?



ការចាក់គ្រឹះឲ្យរឹងមាំ ប្រៀបបានទៅនឹងការថែទាំខាងវិញ្ញាណដូច្នោះដែរ នេះមានន័យថា បុគ្គលម្នាក់ត្រូវបន្តជួយដល់អ្នកដែលជឿថ្មីៗ ដើម្បីឲ្យអ្នកនោះពេញវ័យខាងវិញ្ញាណ ហើយមានប្រយោជន៍ក្នុងព័ន្ធកិច្ចរបស់ព្រះជាម្ចាស់។

២. តើសាវ័ក ពេត្រុស បានប្រៀបធៀបការរីកចម្រើនខាងវិញ្ញាណទៅនឹងអ្វី? (១ពេត្រុស ២:១-៣)

ក) ហេតុអ្វីបានជាកូនតូចៗត្រូវការជំនួយពីឪពុកម្ដាយ?

ខ) តើលោកអ្នកចាត់ទុកខ្លួនឯងថាជាទារករបស់ព្រះគ្រីស្ទ ឬក៏ជាកូនដែលកំពុងតែពេញវ័យខាងវិញ្ញាណ? សូមពន្យល់៖

៣. ព្រះយេស៊ូវគ្រីស្ទសព្វព្រះហឫទ័យឲ្យសេចក្ដីស្រឡាញ់របស់ទ្រង់ទ្វេរគុណឡើង ហេតុដូច្នេះហើយបានជាទ្រង់ប្រទានមហាបេសកកម្មទៅដល់អ្នកដើរតាមទ្រង់ ដើម្បីឈោងចាប់មនុស្សលោកដោយដំណឹងល្អរបស់ទ្រង់។ តើទ្រង់បានបញ្ជាឲ្យពួកគេចូលរួមចំណែកអ្វីខ្លះក្នុងមហាបេសកកម្មនោះ? (ម៉ាថាយ ២៨:១៨-២០)

៤. ហេតុអ្វីបានជាសាវ័ក ប៉ុល យកចិត្តទុកដាក់ចំពោះការចាក់គ្រឹះឲ្យរឹងមាំដល់អស់អ្នកដែលគាត់បានឈោងចាប់? (១ថែស្សាឡូនីច ៣:៥, ១៣)

៥. សូមអានកណ្ឌគម្ពីរ កូល៉ុស ១:២៨-២៩ តាមការយល់ឃើញរបស់លោកអ្នកសូមគិតទៅមើលថា ហេតុអ្វីបានជាសាវ័ក ប៉ុល មានបំណងចិត្តចង់ឲ្យមនុស្សទទួលបានការផ្លាស់ប្រែពីព្រះគ្រីស្ទខ្លាំងម្ល៉េះ?

# តម្លៃនៃបុគ្គលនីមួយៗ



ព្រះជាម្ចាស់បានដាក់តម្លៃ និងកិត្តិយសដល់គ្រប់ទាំងមនុស្សដែលទ្រង់បានបង្កើតមក។ ព្រះជាម្ចាស់បានបង្កើតមនុស្សលោកមកឲ្យដូចជារូបអង្គទ្រង់ និងឲ្យមានភាពដូចទ្រង់។ នៅលើចក្រវាលដ៏ធំល្វឹងល្វើយនេះ មានតែយើងទេដែលមានអភ័យឯកសិទ្ធិដាច់ដោយឡែកក្នុងការបង្ហាញពីលក្ខណៈរបស់ព្រះជាម្ចាស់។

៦. កណ្ឌគម្ពីរ លោកុប្បត្តិ ១:២៦-២៨ បើកសម្តែងពីដើមកំណើតរបស់យើង។ តើមនុស្សលោកមានតម្លៃយ៉ាងណាចំពោះព្រះជាម្ចាស់ យោងតាមខគម្ពីរនេះ? ហើយតើតម្លៃនេះកើតចេញមកពីណា?

៧. សូមអានកណ្ឌគម្ពីរ ទំនុកដំកើង ៨:៣-៨។ តើអ្នកនិពន្ធទំនុកដំកើងត្រង់ជំពូកនេះបានបញ្ជាក់ពីតម្លៃរបស់មនុស្សយ៉ាងដូចម្តេច? សូមពន្យល់ថា តើការនេះមានន័យចំពោះលោកអ្នក និងអ្នកផ្សេងទៀតយ៉ាងដូចម្តេច។

៨. តើមានមនុស្សប៉ុន្មាននាក់ដែលសាវ័ក ប៉ុល បានលើកឈ្មោះគេឡើង នៅក្នុងកណ្ឌគម្ពីរ រ៉ូម ១៦? តើការលើកឈ្មោះនេះបង្ហាញពីអ្វីខ្លះ?

៩. តើព្រះយេស៊ូវបានបង្រៀនពីសារៈសំខាន់របស់បុគ្គលនីមួយៗ យ៉ាងដូចម្ដេចខ្លះនៅក្នុងកណ្ឌគម្ពីរ លូកា ១៥:៣-៧?

១០. សូមអានកណ្ឌគម្ពីរ ១កូរិនថូស ៤:១៥។ សូមគិតទៅមើលថា ហេតុអ្វីបានជាសាវ័ក ប៉ុល យកចិត្តទុកដាក់ដោយផ្ទាល់ចំពោះអ្នកក្រុង កូរិនថូស? (សូមពិចារណាពីភាពខុសគ្នារវាង ទឹកចិត្តរបស់អ្នកមើលថែ និងទឹកចិត្តរបស់ឪពុក)។

១១. ស្របពេលដែលលោកអ្នកពិចារណាពីតម្លៃខ្លួនឯង និងតម្លៃរបស់អ្នកដទៃ តើសេចក្តីពិតក្នុងវគ្គ តម្លៃនៃបុគ្គលនីមួយៗ បានប៉ះពាល់ចិត្តលោកអ្នកយ៉ាងដូចម្តេច?

## ការជួយអ្នកដទៃទៀតឲ្យមានការលូតលាស់



១២. តើសាវ័ក ប៉ុល និងគូកនរបស់គាត់បានធ្វើអ្វីខ្លះ ដើម្បីជួយដល់អស់អ្នកដែលទើបនឹងជឿលើព្រះយេស៊ូវគ្រីស្ទថ្មីៗ?
កិច្ចការ ១៤:២១-២២

កិច្ចការ ១៨:១១

១៣. តើសាវ័ក ប៉ុល និងគូកនរបស់គាត់បានអធិស្ឋានពីអ្វីខ្លះឲ្យអ្នកជឿថ្មីៗ?
កូល៉ុស ១:៩-១២

កូល៉ុស ៤:១២

១៤. តើលោកអ្នកគួរលើកទឹកចិត្តដល់អ្នកដែលទើបនឹងជឿថ្មីៗឲ្យធ្វើអ្វីខ្លះ?
(កូល៉ុស ៣:១៦)

១៥. តើមានចំណុចត្រង់ណាផ្សេងទៀតដែលលោកអ្នកគួរលើកទឹកចិត្ត និងជួយចាក់គ្រឹះដល់ពួកគេឲ្យរឹងមាំ?
ម៉ាកុស ៥:១៩

លូកា ៩:២៣

យ៉ូហាន ១៥:១០

ភីលីព ៤:៦

ហេព្រើរ ១០:២៥

“ *ព្រះយេស៊ូវមានបំណងព្រះហឫទ័យឲ្យក្រុមជំនុំរបស់ទ្រង់លូតលាស់តាមរយៈការប្រកបជាមួយអ្នកជឿដូចគ្នា។ មួយទៀត ទ្រង់ក៏មានបំណងព្រះហឫទ័យឲ្យក្រុមជំនុំរបស់ទ្រង់បណ្តុះបណ្តាលឲ្យមានអ្នកដឹកនាំដែលជួយជំរុញអ្នកផ្សេងទៀតឲ្យបំពេញព័ន្ធកិច្ចរបស់ព្រះជាម្ចាស់។*

លោកបណ្ឌិត អ៊ែរិក សាន់ដ្រាស៍ (Eric Sandras, PhD)

ដកស្រង់ចេញពីសៀវភៅ *Buck-Naked Faith*

១៦. សាវ័ក ប៉ុល បានប្រើវិធីសាស្ត្រផ្សេងៗជាច្រើន ដើម្បីថែបំប៉នអ្នកទើបនឹងជឿថ្មីៗ។ តើខគម្ពីរខាងក្រោមនេះពណ៌នាពីវិធីសាស្ត្រអ្វីខ្លះ?

កិច្ចការ ១៥:៣៦

១កូរិនថូស ៤:១៤

១កូរិនថូស ៤:១៧

២ធីម៉ូថេ ១:៣

តើលោកអ្នកអាចជួយអ្នកដែលលោកអ្នកស្គាល់ដោយប្រើវិធីសាស្ត្រមួយនៅក្នុងចំណោមវិធីសាស្ត្រទាំងអស់នេះយ៉ាងដូចម្តេច?

លោកអ្នកគួរជួយបង្រៀនអ្នកជឿថ្មីៗឲ្យយល់ដឹងពីចំណុចខាងក្រោមនេះ៖

- ការធានាអះអាងថា គេបានទទួលសេចក្តីសង្គ្រោះ និងសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់
- ពេលវេលាស្ងៀមស្ងាត់ថ្វាយបង្គំព្រះជាម្ចាស់ផ្ទាល់ខ្លួនជាប្រចាំ
- ការទន្ទេញ និងការសញ្ជឹងគិតលើបទគម្ពីរ
- ការសិក្សាព្រះគម្ពីរ (គឺជាការនាំឲ្យគេយល់ពីទស្សនៈរបស់ព្រះជាម្ចាស់)
- ការអធិស្ឋាន (ការសន្ទនាផ្ទាល់ខ្លួនជាមួយនឹងព្រះជាម្ចាស់)
- ការប្រកបគ្នាជាមួយនឹងអ្នកជឿផ្សេងៗទៀត
- ការផ្សាយដំណឹងល្អពីព្រះគ្រីស្ទដល់អ្នកផ្សេងៗទៀត
- ការរីកចម្រើននៅក្នុងសេចក្តីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត ដឹងខ្នាត (ផលផ្លែខាងឯវិញ្ញាណ)
- ការរៀនជឿទុកចិត្ត ហើយស្តាប់បង្គាប់ព្រះជាម្ចាស់នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ និងការសម្រេចចិត្តផ្សេងៗ
- ការបម្រើអ្នកទាល់ក្រ

## ការរស់នៅជាគំរូ



*នៅពេលថៃបំប៉នអ្នកណាម្នាក់ អ្នកនោះនឹងសម្លឹងមើលពីគំរូរបស់លោកអ្នកជាជាងការបង្រៀនរបស់លោកអ្នកទៅទៀត។*

លោក ដរ៍សាន់ ច្រតមែន (Dawson Trotman)

១៧. តើសាវ័ក ប៉ុល បានមានប្រសាសន៍អ្វីខ្លះអំពីគំរូរបស់គាត់ទៅកាន់ក្រុមជំនុំភីលីព? (ភីលីព ៤:៩)

១៨. សូមអានកណ្ឌគម្ពីរ ១ធីម៉ូថេ ៤:១២។ តើមានចំណុចត្រង់ណាខ្លះដែលលោកអ្នកគួរតែធ្វើជាគំរូដល់អ្នកដទៃ?

> *ព្រះយេស៊ូវបានបន្សល់ទុកនូវគំរូដ៏សំខាន់បំផុតសម្រាប់ការបង្កើតសិស្សដោយបើកចំហចិត្ត ហើយមិនលាក់លៀមអ្វីបន្តិចសោះឡើយ។ សិស្សរបស់ទ្រង់បានរស់នៅរួមសុខរួមទុក្ខជាមួយនឹងទ្រង់រៀងរាល់ថ្ងៃ។ ពួកគេបានឃើញទ្រង់យ៉ាងពេញលេញមិនមែនត្រឹមតែការអស្ចារ្យដែលទ្រង់បានសម្ដែងឡើងនោះទេ ប៉ុន្តែពួកគេថែមទាំងបានឃើញទ្រង់ជាបុរសម្នាក់ដែលមានព្រះហឫទ័យក្តួលអាណិតមកពីព្រះវរបិតា ហើយពួកគេក៏បានឃើញទ្រង់ខ្លាច់ និងព្រះកន្សែងផងដែរ។ ការបណ្ដាក់ទុនរបស់ព្រះយេស៊ូវក្នុងជីវិតរបស់ពួកគេនឹងទទួលបានមកវិញនូវផលផ្លែដ៏*

*ច្រើនអរនេកក្រោយពេលដែលទ្រង់យាងទៅស្ថានសួគ៌វិញ។ ដូចគ្នានេះដែរ យើងក៏ត្រូវដាក់ទុនក្នុងជីវិតរបស់បងប្អូនប្រុសស្រីរួមជំនឿរបស់យើង ដើម្បីឲ្យពួកគេមានការរីកចម្រើននៅក្នុងជំនឿផងដែរ។*

លោកស្រី ផែមមិលឡា ធូស័នថ៌ (Pamela Toussaint)

ដកស្រង់ចេញពីសៀវភៅ *Homemade Disciples*

១៩. ហេតុអ្វីបានជាការរស់ដោយបើកចំហចិត្តមានសារៈសំខាន់ម្ល៉េះ នៅពេលដែលយើងរស់នៅជាគំរូដល់អ្នកដទៃ?

២០. តើលោកអ្នកហ៊ាននិយាយដូចសាវ័ក ប៉ុល ថា៖ “ចូរត្រាប់តាមខ្ញុំ ដូចជាខ្ញុំបានត្រាប់តាមព្រះគ្រីស្ទដែរ” ឬទេ (១កូរិនថូស ១១:១)? តើមានទិដ្ឋភាពបែបណាខ្លះនៅក្នុងជីវិតរបស់លោកអ្នកដែលគួរតែផ្លាស់ប្តូរ ដើម្បីឲ្យលោកអ្នកអាចរក្សាគំរូឲ្យបានល្អ?

២១. សូមគិតអំពីមនុស្សម្នាក់ដែលលោកអ្នកបាននាំគាត់មកជឿលើព្រះគ្រីស្ទ ឬក៏នរណាម្នាក់ដែលលោកអ្នកស្គាល់ជាអ្នកដែលទើបនឹងជឿថ្មីៗ។ សូមនឹកចាំហើយអធិស្ឋានសម្រាប់គាត់ ព្រមទាំងពិចារណាមើលថា

តើលោកអ្នកមានមធ្យោបាយណាផ្សេងទៀតដែលអាចជួយបង្ហាត់បង្រៀនគាត់ឲ្យមានការលូតលាស់ខាងឯវិញ្ញាណបន្ថែមទៀតបាន។ តើលោកអ្នកគួរតែទៅសួរសុខទុក្ខដោយផ្ទាល់ ឬក៏ទូរស័ព្ទសួរសុខទុក្ខ ឬសរសេរជាសំបុត្រទៅគាត់? តើលោកអ្នកមានធនធានអ្វីខ្លះដែលអាចឲ្យគាត់យកទៅប្រើប្រាស់ ដើម្បីជួយគាត់ឲ្យមានការលូតលាស់? តើលោកអ្នកគួរតែនាំគាត់ទៅលេងមិត្រភក្តិដែលមិនជឿ ឬនាំគាត់ទៅលេងអ្នកដែលទើបនឹងជឿថ្មីៗដូចគ្នា? សូមសង្ខេបពីរបៀបដែលលោកអ្នកអាចជួយដល់គាត់ និងពីអ្វីដែលលោកអ្នកបម្រុងនឹងធ្វើ។

> *សហគមន៍អ្នកជឿដែលចេះថែទាំជំនឿ នោះនឹងបង្កើតឲ្យមានអ្នកដើរតាមដែលនឹងចេះថែទាំជំនឿអ្នកផ្សេងទៀតដែរ។ ក្រុមជំនុំដំបូងបានអនុញ្ញាតឲ្យព្រះវិញ្ញាណបរិសុទ្ធប្រើពួកគេឲ្យទៅបម្រើ ហើយស្រឡាញ់អ្នកផ្សេងៗទៀត ព្រមទាំងអនុញ្ញាតឲ្យព្រះវិញ្ញាណបំផ្លាស់បំប្រែជីវិតរបស់ពួកគេ តាមរយៈការថ្វាយបង្គំទ្រង់ និងការសិក្សា*

*ព្រះបន្ទូល។ នោះហើយគឺជាផ្លូវនៃឈើឆ្កាង។ ចូរចេញទៅបង្កើតសិស្ស ស្របពេលដែលយើងកំពុងត្រាប់តាមព្រះយេស៊ូវដែលជាម្ចាស់យើង។*

លោកបណ្ឌិត អ៊ែរិក សាន់ដ្រាស់ (Eric Sandras, PhD)

ដកស្រង់ចេញពីសៀវភៅ *Buck-Naked Faith*

## សំណើខគម្ពីរមួយសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់



១ថែស្សាឡូនីច ២:៨

គឺយ៉ាងនោះហើយដែលយើងខ្ញុំបានស្រឡាញ់ដល់អ្នករាល់គ្នា ដល់ម្ល៉េះបានជាយើងខ្ញុំចូលចិត្តចែកដំណឹងល្អពីព្រះ មកអ្នករាល់គ្នា មិនត្រឹមតែប៉ុណ្ណោះ ក៏ចូលចិត្តចែកទាំងជីវិតយើងខ្ញុំផង ដោយព្រោះអ្នករាល់គ្នាបានត្រឡប់ជាស្ងួនភ្ងាដល់យើងខ្ញុំ។

១ថែស្សាឡូនីច ២:៨

## សៀវភៅកំណត់ហេតុរបស់ខ្ញុំ

សូមសញ្ជឹងគិតពីរបៀបដែលអ្នកដើរតាមព្រះយេស៊ូវបានប្រព្រឹត្តចំពោះលោកអ្នក នៅពេលដែលលោកអ្នកចាប់ផ្ដើមដើរតាមព្រះជាម្ចាស់ដូចពួកគេ។ តើពួកគេបានយកចិត្តទុកដាក់ ឬក៏មិនយកចិត្តទុកដាក់ចំពោះលោកអ្នកយ៉ាងដូចម្ដេចខ្លះ? តើពួកគេគាំទ្រ ឬក៏បោះបង់លោកអ្នកចោល តាមរបៀបណាខ្លះ? តើចំណុចណាមានសារប្រយោជន៍បំផុតចំពោះលោកអ្នក? តើចំណុចណាដែលជួយលោកអ្នកបានតិចបំផុត? តើលោកអ្នកអាចរៀនពីអ្នកដែលបានជួយលោកអ្នកក្នុងការដើរជាមួយនឹងព្រះយេស៊ូវ ដើម្បីយកទៅជួយអ្នកផ្សេងទៀតបានយ៉ាងដូចម្ដេច?

# ចំណុចគួរចងចាំ

សូមពិនិត្យប្រធានបទបន្ទាប់បន្សំនៅក្នុងជំពូកនេះឡើងវិញ ហើយយកវាមកធ្វើជាគម្រោងមេរៀន ដើម្បីសង្ខេបជំពូកនេះដោយគំនិតលោកអ្នកផ្ទាល់។

# ការចូលឲ្យបានស៊ីជម្រៅ

សូមប្រើសំបុត្រទី១របស់សាវ័ក ប៉ុល ដែលគាត់បានផ្ញើទៅកាន់ក្រុមជំនុំថែស្សាឡូនីចទុកជាលំនាំនៃការអនុវត្ត ដើម្បីជួយចាក់គ្រឹះដល់អ្នកជឿថ្មីម្នាក់ដែលលោកអ្នកស្គាល់ឲ្យរឹងមាំ។ នៅពេលដែលលោកអ្នកអានជំពូកនីមួយៗនៃកណ្ឌគម្ពីរ ១ថែស្សាឡូនីចសូមឆ្លើយសំណួរខាងក្រោមនេះ៖

- តើសាវ័ក ប៉ុល មានឥរិយាបថ និងឆន្ទៈចំពោះអ្នកនៅក្នុងក្រុងថែស្សាឡូនីចបែបណា?

- តើគាត់បានស្គាល់ចិត្តរបស់ពួកគេប៉ុណ្ណា ហើយគាត់បានរួមចំណែកជីវិតជាមួយពួកគេយ៉ាងដូចម្តេច?

- តើគាត់បានអធិស្ឋានសម្រាប់ពួកគេយ៉ាងដូចម្តេច?

- តើគាត់បានធ្វើអ្វី ដើម្បីចាក់គ្រឹះពួកគេឲ្យរឹងមាំ?

- តើគាត់បានផ្ដោតការបង្រៀនទៅលើអ្វី?

- តើមានការអ្វីខ្លះដែលគាត់មិនបានធ្វើនៅក្នុងចំណោមពួកគេ?

**គន្លឹះជំនួយៈ**

កំហុសមួយដែលកើតឡើងជារឿយៗក្នុងការថែបំប៉នមនុស្សម្នាក់ទល់ម្នាក់គឺ ការដែលគេបានប៉ាន់ប្រមាណថា អស់អ្នកដែលជឿថ្មីៗសុទ្ធតែមានលក្ខណសម្បត្តិគ្រាប់គ្រាន់ ដើម្បីទទួលយកការហ្វឹកហាត់មេរៀនជ្រៅៗបាន។ ប៉ុន្តែវិធីសាស្រ្តនេះអាចធ្វើឲ្យអ្នកជឿថ្មីៗនោះយល់ឃើញថា ការរីកចម្រើនរបស់គ្រីស្ទបរិស័ទជាបន្ទុកដ៏ធ្ងន់ មិនមែនជាការសប្បាយនោះទេ។ សូមចងចាំថា មនុស្សភាគច្រើនមិនដែលបានទទួលជំនួយខាងឯវិញ្ញាណតាមរបៀបការថែបំប៉នមនុស្សម្នាក់ទល់ម្នាក់យ៉ាងទៀងទាត់នោះទេ។ ពួកគេភាគច្រើនត្រូវការ ការលើកទឹកចិត្តបែបម្ដាយថែរក្សាកូន ជាជាងការប្រាប់ឲ្យពួកគេធ្វើអ្វីមួយ។ ឯអ្នកផ្សេងទៀត

ដែលមានគ្រឹះខាងវិញ្ញាណមាំជាង អ្នកនោះនឹងកាន់តែចាប់អារម្មណ៍ចំពោះការបង្រៀនដែលមានលក្ខណៈដូចជាទំនាក់ទំនងរវាងឪពុក និងកូនថែមទៀត។ ហើយប្រសិនបើ មានអ្នកផ្សេងដែលពេញវ័យខាងវិញ្ញាណ នោះយើងគួរមានទំនាក់ទំនងជាមួយពួកគេបែបជាបងប្អូនវិញ។*

* មកពី Richard Cleveland, “Follow-Up: Person to Person,” Discipleship Journal, វិច្ឆិកា/ធ្នូ ឆ្នាំ១៩៨១, ទំព័រ១១ ។

ជំពូកទី

# ៥

# ទស្សនៈពិភពលោក

ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ចំពោះបុគ្គលម្នាក់ៗគ្រប់ជាតិសាសន៍។ យើងឃើញថា មានមនុស្សរាប់កោដិនាក់កំពុងរស់នៅលើពិភពលោកសព្វថ្ងៃនេះ ហើយយើងប្រហែលជាឆ្ងល់ថា តើយើងអាចប្រាប់មនុស្សរាប់កោដិនាក់នោះពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់យ៉ាងមានប្រសិទ្ធភាពបានយ៉ាងដូចម្ដេច។ របៀបដែលព្រះជាម្ចាស់ឲ្យយើងធ្វើកិច្ចការនេះគឺ តាមរយៈការផ្សាយដំណឹងល្អ ដើម្បីបណ្ដុះបណ្ដាលឲ្យមានអ្នកជឿថ្មីៗ ហើយពេលនោះពួកគេនឹងបង្កើតផលផ្លែផ្សេងទៀតនៅជុំវិញពិភពលោក។

> “ *ព្រះជាម្ចាស់កំពុងតែទតមើលពិភពលោកនេះដោយព្រះហឫទ័យក្ដួលអាណិត ហើយទស្សនៈពិភពលោកដ៏ពិតគឺជាការមើលឃើញពិភពលោកដូចទ្រង់យ៉ាងដូច្នេះដែរ*
>
> លោក ដ័សាន់ ថ្រតមែន (Dawson Trotman)

# ព្រះទ័យទុកដាក់របស់ព្រះជាម្ចាស់ចំពោះមនុស្សលោក



១. តើកណ្ឌគម្ពីរ យ៉ូហាន ៣:១៦ និង២ពេត្រុស ៣:៩ បានបង្ហាញពីវិសាលភាពនៃការយកព្រះទ័យទុកដាក់របស់ព្រះជាម្ចាស់ចំពោះមនុស្សលោកយ៉ាងដូចម្ដេច?

២. ព្រះជាម្ចាស់បានបង្ហាញចក្ខុវិស័យដ៏អស្ចារ្យមួយមកពីស្ថានសួគ៌ដែលមាននៅក្នុងកណ្ឌគម្ពីរ វិវរណៈ ៧:៩-១០។ តើនរណាជាអ្នកដែលមានវត្តមានជាមួយព្រះជាម្ចាស់ ហើយលោកអ្នកយល់ថា អ្នកនោះទៅទីនោះបានដោយរបៀបណា?

៣. គម្រោងការរបស់ព្រះជាម្ចាស់តាមរយៈមនុស្សត្រូវតែបានសម្រេចជាមុនសិន ដើម្បីឲ្យនិមិត្តដែលបានបើកសម្ដែងនៅក្នុងកណ្ឌគម្ពីរ វិវរណៈ ៧:៩-១០ កើតឡើងបាន។ ព្រះយេស៊ូវបានដាក់ទុនយ៉ាងច្រើនទៅលើមនុស្សមួយចំនួន ដើម្បីឲ្យពួកគេទ្វេរគុណឲ្យមានអ្នកជឿច្រើនឡើងជាលំដាប់លំដោយ។ ទ្រង់ក៏បានពន្យល់ពីតួនាទីរបស់យើងនៅក្នុងគម្រោងការរបស់ព្រះជាម្ចាស់ដែរ។ ដូច្នេះ តើព្រះយេស៊ូវបានមានបន្ទូលពីមហាបេសកកម្មទ្រង់យ៉ាងដូចម្ដេច យោងតាមខគម្ពីរខាងក្រោមនេះ?
ម៉ាថាយ ២៨:១៩-២០

ម៉ាកុស ១៦:១៥

លូកា ២៤:៤៧

យ៉ូហាន ១៧:១៨, ២០:២១

កិច្ចការ ១:៨

តើព្រះជាម្ចាស់សព្វព្រះហឫទ័យប្រើប្រាស់យើង ដើម្បីឲ្យយើងជួយអ្នកដទៃឲ្យមានការលូតលាស់ខាងឯវិញ្ញាណយ៉ាងដូចម្ដេច?

វាពិតជាគួរឲ្យស្ងើចសរសើរណាស់ពីការមាននិមិត្តឈោងចាប់ បុគ្គលណាម្នាក់ សិស្សសាកលវិទ្យាល័យ ទាហាននៅបន្ទាយ អ្នកនៅកន្លែងធ្វើការ អ្នកជិតខាង សហគមន៍ រួមទាំងជាតិសាសន៍ទាំងមូលថ្វាយព្រះគ្រីស្ទនោះ។ ប៉ុន្តែព្រះទ័យរបស់ព្រះជាម្ចាស់គឺ ឈោងចាប់សាកលលោកទាំងមូលតែម្ដង ហើយនេះក៏គួរតែជាអ្វីដែលយើងគួរចង់បានផងដែរ។ នៅក្នុងមហាបេសកកម្ម ព្រះយេស៊ូវបានប្រទានទំនួលខុសត្រូវ និងអភ័យឯកសិទ្ធិដល់អ្នកជឿទាំងអស់ ដើម្បីឈោងចាប់មនុស្សគ្រប់ជាតិសាសន៍ នៅគ្រប់ទាំងជំនាន់ទាំងអស់ដោយដំណឹងល្អរបស់ទ្រង់។ រាល់ការសម្រេចចិត្តដ៏សំខាន់ៗក្នុងឆាកជីវិតរបស់យើង ត្រូវតែធ្វើឡើងដើម្បីជាប្រយោជន៍ដល់មហាបេសកកម្មរបស់ព្រះគ្រីស្ទ។

# ពិភពលោកសព្វថ្ងៃ



៤. សូមសង្ខេបពីរបៀបដែលខគម្ពីរខាងក្រោមពណ៌នាអំពីស្ថានភាពពិភពលោកនៅគ្រាចុងក្រោយ។

១ធីម៉ូថេ ៤:១-៣

២ធីម៉ូថេ ៣:១-៥

២ពេត្រុស ៣:៣-៥

សូមគូររង្វង់ជុំវិញលើស្ថានភាពដែលលោកអ្នកបានសរសេរដែលមើលទៅហាក់ដូចជាស្ថានភាពជាក់ស្តែងនៅសព្វថ្ងៃនេះ។

៥. តើមានអ្វីដែលកំពុងរង់ចាំអស់អ្នកដែលបដិសេធដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ? (២ថែស្សាឡូនីច ១:៨-៩, វិវរណៈ ២០:១២, ១៥)

៦. នៅពេលដែលព្រះយេស៊ូវបានទតឃើញពីតម្រូវការរបស់មនុស្សនៅជុំវិញទ្រង់ តើទ្រង់បានឲ្យសិស្សរបស់ទ្រង់អធិស្ឋានពីអ្វី? (ម៉ាថាយ ៩:៣៦-៣៨)

តើអ្នករាល់គ្នាមិនថា នៅ៤ខែទៀត ទើបដល់រដូវចំរូតទេឬអី ខ្ញុំប្រាប់អ្នករាល់គ្នាថា ចូរងើបឡើងមើលទៅស្រែមើល ដ្បិតបានក្រហមល្មមច្រូតហើយ (យ៉ូហាន ៤:៣៥)

# ប្រជាជនសរុបនៅលើពិភពលោកទាំងមូលមានប្រមាណជា ៧.១៥២.៧៣៦.៣០០នាក់ និងមានការកើនឡើងគ្រប់វិនាទី។*

«នៅក្នុងព្រះគ្រិស្ត ព្រះជាម្ចាស់កំពុងផ្សះផ្សាលោកិយនេះជាមួយព្រះអង្គ» (២កូរិនថូស ៥:១៩ គបខ)




ដកស្រង់ចេញពី៖ Population Division of the Department of Economic and Social Affairs of the United States Secretariat, *World Population Prospects; The ២០០២ Revision and Urbanization Prospects; The ២០០១ Revision.*




ដកស្រង់ចេញពី The World Factbook, "People and Society," https://www.cia.gov/library/publications/the-world-factbook/geos/xx.html (បានកំណត់យកនៅថ្ងៃទី ៤ ខែមេសា ឆ្នាំ២០១៤)

---

* មកពី U.S. Census Bureau, International Programs Center, http://www.census.gov/main/www/popclock.html (កំណត់យកនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៤)

**“ចូរងើបឡើងមើលទៅស្រែមើល”**

ខាងក្រោមនេះ គឺជារបៀបនៃការអនុវត្តមួយចំនួនដើម្បី “ងើបឡើងមើលទៅស្រែមើល”៖

- សូមប្រើផែនទីពិភពលោក ហើយអធិស្ឋានសម្រាប់ប្រទេសនីមួយៗនៅជុំវិញពិភពលោក ដើម្បីឲ្យមនុស្សនៅផែនដីនេះជឿព្រះគ្រីស្ទ ហើយលូតលាស់ក្នុងការដើរជាមួយទ្រង់។
- សូមអធិស្ឋានសម្រាប់អ្នកជឿទាំងអស់ និងអ្នកដឹកនាំក្រុមជំនុំនៅជុំវិញពិភពលោកដែលទទួលការបៀតបៀន។
- ចូរមានទំនាក់ទំនងជាមួយបេសកជន ហើយរៀនពីបទពិសោធន៍បេសកកម្ម និងពីអង្គការរបស់ពួកគេ។
- សូមអានពីជីវប្រវត្តិបេសកជន សៀវភៅបេសកកម្ម និងយុគសម័យរបស់បេសកជន។
- សូមអធិស្ឋានឲ្យលោកអ្នកមានទំនាក់ទំនងជាមួយអ្នកមិនជឿ ដើម្បីឲ្យលោកអ្នកអាចបង្ហាញពីសេចក្ដីស្រឡាញ់របស់ព្រះយេស៊ូវទៅកាន់ពួកគេបាន។
- សូមដាក់ប្រាក់តង្វាយដើម្បីជួយផ្គត់ផ្គង់អ្នកជឿផ្សេងៗ និងបេសកជនផ្សេងៗដែលកំពុងបម្រើព័ន្ធកិច្ចរបស់ព្រះជាម្ចាស់នៅប្រទេសផ្សេងៗទៀត។

**ជំនាន់ខាងឯវិញ្ញាណ**

បើយើងស្គាល់ពីស្ថានភាពឲ្យទាន់ហេតុការណ៍ ហើយអធិស្ឋានជាប្រចាំព្រមទាំងចេះផ្ដល់ឲ្យអ្នកដទៃ នោះយើងនឹងមានចំណែកក្នុងការឈោងចាប់មនុស្សលោកដោយដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។ ហើយយើងអាចធ្វើការនេះដោយផ្ទាល់តាមរយៈការផ្សាយដំណឹងល្អដល់អ្នកផ្សេងៗ។ តាមរយៈការទាំងអស់នេះ យើងគួរតែបន្តទុកចិត្តថា ព្រះជាម្ចាស់នឹងទ្វេរគុណជំនាន់នៃ

អ្នកដើរតាមទ្រង់នៅជុំវិញពិភពលោកជាមិនខាន មិនថាជាយើងរស់នៅបានឃើញ ឬមិនបានឃើញព្រឹត្តិការណ៍នេះកើតឡើងឬអត់នោះទេ។ ការនេះរួមមានទាំងជំនាន់ខាងឯវិញ្ញាណ និងខាងសាច់ឈាមផងដែរ។

៧. តើព្រះជាម្ចាស់បានសន្យាអ្វីចំពោះលោក អ័ប្រាហាំ?
(លោកុប្បត្តិ ២២:១៧-១៨)



៨. ព្រះយេស៊ូវបានរស់នៅក្នុងជំនាន់ប្រជាកសិករ ហើយទ្រង់បានប្រើពាក្យប្រដូចខាងស្រែចម្ការ និងពីគ្រាប់ពូជពីការលូតលាស់បែបធម្មជាតិ ដើម្បីពណ៌នាពីជំនាន់ខាងឯវិញ្ញាណ។
សូមអានកណ្ឌគម្ពីរ ម៉ាថាយ ១៣:៣១-៣២។ តើនគររបស់ព្រះជាម្ចាស់លូតលាស់យ៉ាងដូចម្តេច?

បើលោកអ្នកមានបំណងចង់សិក្សាព្រះបន្ទូលបន្ថែមទៀតសូមមើលកណ្ឌគម្ពីរ ម៉ាកុស ៤:១-២០ ម៉ាកុស ៤:២៦-២៩ និងយ៉ូហាន ១២:២៣-២៦។

ក្នុងអំឡុងពេលដែលព្រះយេស៊ូវទទួលទានអាហារចុងក្រោយរបស់ទ្រង់ជាមួយនឹងពួកសិស្ស ពេលនោះទ្រង់បានអធិស្ឋានសម្រាប់ពួកគេ និងសម្រាប់សិស្សជំនាន់ក្រោយៗផងដែរ។ ទ្រង់បានទូលសូមព្រះជាម្ចាស់ឲ្យនៅតែបន្តប្រតិបត្តិការតាមរយៈសិស្សរបស់ទ្រង់ចំពោះមនុស្សដែលបាត់បង់នៅលើលោកីយ៍។ ព្រះយេស៊ូវបានដាំគ្រាប់ពូជដោយការអធិស្ឋានទុកសម្រាប់ពេលអនាគត ហើយទ្រង់ក៏បានទូលសូមព្រះជាម្ចាស់ឲ្យចម្រើនគ្រាប់ពូជនោះទ្វេរគុណឡើងផងដែរ។

៩. សូមអានកណ្ឌគម្ពីរ យ៉ូហាន ១៧:៥-២៦ ដោយយកចិត្តទុកដាក់ហើយគិតទៅលើសេចក្ដីអធិស្ឋានរបស់ព្រះយេស៊ូវ។ ប្រសិនបើលោកអ្នកជាសិស្សរបស់ព្រះយេស៊ូវ នោះមានន័យថា ទ្រង់បានអធិស្ឋានឲ្យលោកអ្នកហើយ! សូមឆ្លើយសំណួរខាងក្រោមនេះ៖

- តើលោកអ្នកមានយោបល់ពីនិមិត្តរបស់ព្រះយេស៊ូវដែលទ្រង់ចង់ឃើញសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់នឹងឈោងចាប់មនុស្សលោកតាមរយៈជំនាន់នៃសិស្សរបស់ទ្រង់យ៉ាងដូចម្ដេច?

- តើព្រះយេស៊ូវមានសំណូមពរអធិស្ឋានអ្វីខ្លះសម្រាប់យើង ស្របពេលដែលយើងបំពេញនិមិត្តរបស់ទ្រង់?

• តើព្រះយេស៊ូវបានរៀបចំយើងយ៉ាងដូចម្ដេច ដើម្បីបំពេញនិមិត្តរបស់ទ្រង់?

## តើលោកអ្នកអាចសម្របខ្លួនក្នុងការនេះយ៉ាងដូចម្ដេច?



ព្រះយេស៊ូវស្រឡាញ់មនុស្សលោកនេះទាំងអស់ ហើយទ្រង់បានជួយមនុស្សរាប់ពាន់នាក់ ប៉ុន្តែមនុស្សដែលទ្រង់បានហ្វឹកហ្វឺនយ៉ាងខ្លាំងនោះមានតែមនុស្សដប់ពីរនាក់ដែលជាសាវ័ករបស់ទ្រង់ប៉ុណ្ណោះ។ ទ្រង់បានទតឃើញជំនាន់ខាងវិញ្ញាណមានការរីកចម្រើនទ្វេរគុណឡើងតាមរយៈសិស្សទាំងដប់ពីរនោះ។

> *ការស្វែងរកនិមិត្តដែលមកពីព្រះជាម្ចាស់ គឺជាសកម្មភាពមួយនៃការថ្វាយបង្គំទ្រង់។ នៅពេលដែលយើងស្វែងរកនិមិត្តពីព្រះជាម្ចាស់ នោះបញ្ជាក់ថា យើងទុកចិត្តលើទ្រង់ ហើយយល់ព្រមថា របៀបវារៈរបស់ទ្រង់សំខាន់បំផុត។ តាមរយៈការនេះ នោះព្រះជាម្ចាស់នឹងបានទទួលការលើកតម្កើង។*

លោក អែនឌី ស្ដែនលី (Andy Stanley)

ដកស្រង់ចេញពីសៀវភៅ *Visioneering*

១០. នៅពេលដែលលោកអ្នកសញ្ជឹងគិតទៅលើកណ្ឌគម្ពីរ យ៉ូហាន ១៧:៥-២៦ឡើងវិញ តើលោកអ្នកមើលឃើញពីខ្លួនឯងនៅក្នុងសេចក្ដីអធិស្ឋាននេះយ៉ាងដូចម្ដេចខ្លះ? តើលោកអ្នកនឹងទូលសូមអ្វីពីព្រះជាម្ចាស់ ដើម្បីបំពេញបេសកកម្មដែលទ្រង់ប្រទានឲ្យលោកអ្នក?

១១. សូមពិចារណាទៅលើកណ្ឌគម្ពីរ ២ធីម៉ូថេ ២:២។ តើលោកអ្នកធ្លាប់អធិស្ឋានទូលសូមឲ្យព្រះជាម្ចាស់ប្រទាននរណាម្នាក់ដែលលោកអ្នកអាចយកខគម្ពីរត្រង់នេះមកអនុវត្តជាក់ស្ដែងចំពោះអ្នកនោះដែរឬទេ?

ក) លោកអ្នកអាចជួយបំផ្លាស់បំប្រែលោកីយ៍នេះថ្វាយព្រះយេស៊ូវគ្រីស្ទបាន ដោយអនុញ្ញាតឲ្យព្រះជាម្ចាស់បណ្ដុះជីវិតរបស់ទ្រង់នៅក្នុងជីវិតអ្នកដទៃទៀតតាមរយៈលោកអ្នក។ តើលោកអ្នកនឹងអនុញ្ញាតឲ្យព្រះជាម្ចាស់ប្រើប្រាស់លោកអ្នកនៅក្នុងផែនការនៃការបង្កើតឲ្យមានជំនាន់អ្នកជឿខាងវិញ្ញាណយ៉ាងជាក់លាក់ដោយរបៀបណា?

ខ) ប្រសិនបើលោកអ្នកមានកូនចៅ តើលោកអ្នកនឹងទុកចិត្តទ្រង់ថា ទ្រង់នឹងបន្តកេរ្ដិ៍ឈ្មោះខាងឯវិញ្ញាណរបស់លោកអ្នកតាមរយៈពួកគេដោយរបៀបណា?

គ) តើមានក្មេងៗណាផ្សេងទៀតដែលលោកអ្នកអាចបង្ហាត់បង្រៀនបាន?

១២. តើលោកអ្នកកំពុងតែវិនិយោគជីវិត ពេលវេលា និងប្រាក់កាសរបស់លោកអ្នកក្នុងគោលបំណងផ្សាយដំណឹងល្អដល់លោកីយ៍នេះឬ? តើលោកអ្នកគួរធ្វើដូចម្ដេច ដើម្បីឲ្យកាន់តែមានចំណែកក្នុងការឈោងចាប់មនុស្សលោកជាមួយនឹងដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ?

# សំណើខគម្ពីរមួយសម្រាប់ការ សញ្ជឹងគិត និងការទន្ទេញចាំមាត់



ម៉ាថាយ ២៨:១៩-២០

ដូច្នេះ ចូរទៅបង្កើតសិស្សពីគ្រប់ជនជាតិ ហើយធ្វើពិធីជ្រមុជទឹក ឲ្យពួកគេនៅក្នុងព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ហើយបង្រៀនពួកគេឲ្យកាន់តាមសេចក្ដីទាំងឡាយ ដែលខ្ញុំបានបង្គាប់ដល់អ្នករាល់គ្នា ហើយមើល ខ្ញុំនៅជាមួយអ្នករាល់គ្នា គ្រប់ពេលវេលារហូតដល់អស់កល្ប។

ម៉ាថាយ ២៨:១៩-២០ (គបខ*)

* ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ

## សៀវភៅកំណត់ហេតុរបស់ខ្ញុំ

ដោយសារព្រះយេស៊ូវបានប្រទានមហាបេសកកម្មដល់លោកអ្នក តើការនោះបានប៉ះពាល់ចិត្តរបស់លោកអ្នកដូចម្តេចខ្លះ? តើលោកអ្នកព្រមទទួលយកបេសកកម្មនេះដែរឬទេ? សូមបញ្ជាក់ពីរបៀបដែលលោកអ្នកប្រាថ្នាចង់បំពេញមហាបេសកកម្មនេះ។

# ចំណុចគួរចងចាំ

សូមពិនិត្យប្រធានបទបន្ទាប់បន្សំនៅក្នុងជំពូកនេះឡើងវិញ ហើយយកវាមកធ្វើជាគម្រោងមេរៀន ដើម្បីសង្ខេបជំពូកនេះដោយគំនិតលោកអ្នកផ្ទាល់។

# ការចូលឲ្យបានស៊ីជម្រៅ

ដើម្បីឲ្យលោកអ្នកមានចំណែកជាមួយនឹងមហាបេសកកម្មកាន់តែច្រើនជាងនេះទៅទៀតនោះ សូមពិចារណាទៅលើជំហានមួយចំនួនដូចខាងក្រោមៈ

- សូមស្វែងរកសេចក្ដីសន្យារបស់ព្រះជាម្ចាស់ក្នុងព្រះបន្ទូលទ្រង់។ ជ្រើសរើសយកសេចក្ដីសន្យាមួយចំនួនមកអធិស្ឋាន ហើយទូលសូមឲ្យព្រះជាម្ចាស់បំពេញសេចក្ដីសន្យាទាំងនោះ។ សូមត្រាប់តាមអស់ "...អ្នកដែលគ្រងបានសេចក្ដីសន្យាទុកជាមរតក ដោយចិត្តជឿ ហើយអត់ធន់វិញ" (ហេព្រើរ ៦:១២)។
- សូមអធិស្ឋានតាមកណ្ឌគម្ពីរ យ៉ូហាន ១៧ និងបទគម្ពីរផ្សេងៗ ស្ដីពីការឈោងចាប់។ នៅពេលដែលលោកអ្នកអធិស្ឋាន ចូរទូលសូមព្រះជាម្ចាស់ប្រទានឲ្យការផ្សាយដំណឹងល្អរបស់លោកអ្នកមានប្រសិទ្ធភាព។
- សូមគិតពីបុគ្គលម្នាក់ ឬពីរនាក់ដែលលោកអ្នកអាចដាក់ទុនដំណឹងល្អរបស់ព្រះជាម្ចាស់។ ចូររំពឹងទុកក្នុងចិត្តថា ថ្ងៃណាមួយព្រះជាម្ចាស់នឹងទ្វេរគុណទុនដែលលោកអ្នកដាក់នោះ ទុកជាប្រយោជន៍ដល់មនុស្សលោក។
- ប្រសិនបើលោកអ្នកមានកូនចៅ សូមបង្រៀនព្រះបន្ទូលដល់ពួកគេដោយយកចិត្តទុកដាក់។ សូមផ្ទេរមរតកខាងឯវិញ្ញាណដែលលោកអ្នកបានទទួលពីព្រះជាម្ចាស់ឲ្យដល់ពួកគេ។ ប្រសិនបើលោកអ្នកមិនមានកូនចៅទេ សូមពិចារណាលើការដាក់ទុនដំណឹងល្អដល់កូនចៅអ្នកដទៃទៀត។
- សូមអធិស្ឋាន ពិភាក្សាគ្នា ហើយត្រូវមានសង្ឃឹមជានិច្ចថានឹងមានជំនាន់ខាងឯវិញ្ញាណ។
- ត្រូវចាំថា សេចក្ដីសង្គ្រោះគឺជារឿងផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ ប៉ុន្តែក៏មិនមែនមានន័យថា វាអាចកើតឡើងបានដោយខ្លួនឯងនោះទេ។ សេចក្ដីសង្គ្រោះនោះគឺសម្រាប់ក្រុមគ្រួសារ មិត្រភក្តិ និងអ្នកនៅតំបន់ដែលទ្រង់បានត្រាស់ហៅយើងឲ្យទៅ។ ហើយនៅពេលដែលពួកគេជឿ នោះពួកគេនឹងចូលរួមជាមួយយើង និងព្រះជាម្ចាស់នៅក្នុងបេសកកម្មរបស់ទ្រង់ដល់ជាតិសាសន៍ទាំងឡាយ។

- សូមចាប់ដៃគូជាមួយនឹងអ្នកផ្សេងទៀត ដើម្បីបំពេញមហាបេសកកម្មរបស់ព្រះយេស៊ូវ។ គ្មាននរណាម្នាក់អាចធ្វើការតែឯងបានទេ។ ចូរទូលសូមព្រះជាម្ចាស់ឲ្យនាំលោកអ្នកស្គាល់អ្នកផ្សេងទៀតដែលជាអ្នកដើរតាមព្រះយេស៊ូវយ៉ាងអស់ពីចិត្ត ហើយសូមបម្រើព្រះជាម្ចាស់ជាមួយគ្នា។

តើក្នុងចំណោមការទាំងនេះ មានការណាមួយដែលលោកអ្នកគួរយកចិត្តទុកដាក់? តើលោកអ្នកនឹងចាប់ផ្តើមយ៉ាងដូចម្តេច?

# សៀវភៅសិក្សាព្រះគម្ពីរដ៏មានសារៈសំខាន់សម្រាប់អ្នកដើរតាមព្រះគ្រីស្ទនៅក្នុងសតវត្សទី២១



គបស១
**ជីវិតរបស់លោកអ្នកនៅក្នុងព្រះគ្រីស្ទ** 978-0-9890481-0-1
លោកអ្នកនឹងរៀនចេះពីការទទួលសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែលមានចំពោះលោកអ្នក និងរបៀបយកព្រះគ្រីស្ទទុកជាគោលនៃជីវិត ព្រមទាំងការរស់នៅដោយអំណាចចេស្តារបស់ព្រះវិញ្ញាណបរិសុទ្ធ។



គបស២
**អ្នកដើរតាមព្រះយេស៊ូវដែលពេញដោយព្រះវិញ្ញាណ** 978-0-9890481-1-8
លោកអ្នកនឹងរៀនចេះពីអត្ថន័យនៃការពេញដោយព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឲ្យការស្តាប់បង្គាប់ ការសិក្សាព្រះគម្ពីរ ការអធិស្ឋាន ការប្រកបគ្នា និងការធ្វើបន្ទាល់ ក្លាយទៅជាទម្លាប់ និងមានន័យពេញលេញនៅក្នុងជីវិតរស់នៅរបស់លោកអ្នក។



គបស៣
**ការដើរជាមួយព្រះគ្រីស្ទ** 978-0-9890481-2-5
លោកអ្នកនឹងរៀនចេះពីចំណុចសំខាន់ៗប្រាំយ៉ាងតាមរយៈសៀវភៅសិក្សាព្រះគម្ពីរដ៏ងាយស្រួលយល់នេះ ដើម្បីឲ្យបានក្លាយជាសិស្សរបស់ព្រះគ្រីស្ទដ៏រឹងមាំ និងកាន់តែពេញវ័យឡើង។



គបស៤
**អត្តចរិតរបស់អ្នកដើរតាមព្រះយេស៊ូវ** 978-0-9890481-3-2
សៀវភៅដ៏ងាយស្រួលយល់នេះនឹងជួយឲ្យលោកអ្នកយកទៅអនុវត្តលើគុណសម្បត្តិ និងគុណតម្លៃនៃភាពជាសិស្សរបស់ព្រះគ្រីស្ទក្នុងការរស់នៅ។



គបស៥
**មូលដ្ឋានគ្រឹះនៃជំនឿ** 978-0-9890481-4-9
សៀវភៅនៃការសិក្សាព្រះគម្ពីរនេះនឹងជួយលោកអ្នកឲ្យយល់ពីព្រះជាម្ចាស់ ព្រះបន្ទូលរបស់ទ្រង់ ព្រះវិញ្ញាណបរិសុទ្ធ និងការតយុទ្ធខាងព្រលឹងវិញ្ញាណ ព្រមទាំងការយាងមកវិញរបស់ព្រះគ្រីស្ទ។



គបស៧
**សេចក្តីសង្ឃឹមរបស់យើងនៅក្នុងព្រះគ្រីស្ទ** 978-0-9890481-6-3
សៀវភៅនៃការសិក្សាកណ្ឌគម្ពីរ ១ថែស្សាឡូនីចនេះ នឹងផ្តល់ជាគំរូដល់លោកអ្នកក្នុងការសិក្សាកណ្ឌគម្ពីរផ្សេងទៀតក្នុងព្រះគម្ពីរ ហើយលោកអ្នកនឹងទទួលបានគោលការណ៍នៃការសិក្សាព្រះគម្ពីរដ៏មានឥទ្ធិពលដែលលោកអ្នកអាចប្រើប្រាស់បានពេញមួយជីវិត។



គបស **សៀវភៅសម្រាប់គ្រូ** 978-0-9890481-7-0
សៀវភៅនេះនឹងផ្តល់នូវការយល់ដឹងដ៏ជ្រៅជ្រះដល់គ្រូបង្រៀន និងព័ត៌មានផ្សេងៗដែលគ្រូបង្រៀនត្រូវដឹង ដើម្បីចែកចាយពីចំណុចសំខាន់នៃភាពជាសិស្សដ៏ពិតជាមួយអ្នកផ្សេងទៀត ទោះបីជាត្រូវបង្រៀនម្នាក់ទល់ម្នាក់ ឬក៏បង្រៀនជាក្រុម។

NavPress
Discipleship Inside Out®

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ
For purchase information please visit
www.cambodianchristianresources.com/dfd